## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **កញ្ញា ឃិន វ៉ាន់ធី**

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ   កញ្ញា ឃិន វ៉ាន់ធី

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ ម៉ាន់ គីមឡេង

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ឃិន ម៉ាន់ធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ លេខកូដថ្នាក់L៤C៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

សូមគោរពសម្តែងការដឹងគុណជូន **លោកឪពុក ហាស់ សុខឿន និងអ្នកម្តាយ ហាស់ ហឿង** ដែលបានបង្កើត និងបានបំពេញករណីយកិច្ចចិញ្ចឹមបីបាច់ថែរក្សានាងខ្ញុំរហូតមក។ អ្វីដែលមិនអាចបំភ្លេចបាន លោកទាំងពីរបានអនុញ្ញាតឱ្យនាងខ្ញុំបានសិក្សារៀនសូត្រ ដោយលោកទាំងពីរបានប្រៀនប្រដៅ ជួយជ្រោមជ្រែង ទំនុកបម្រុងទាំងថវិកា កម្លាំងចិត្ត និងផ្តត់ផ្គង់ផ្សេងៗទៀតច្រើនរាប់មិនអស់ដោយមិនបានរអ៊ូរទាំចំពោះកូនឡើយ។

សូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រគ្រប់រូប** ក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលតែងបង្ហាត់បង្ហាញនាងខ្ញុំតាំងពីការចាប់ផ្តើមសិក្សាក្នុងឆ្នាំមូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រដោយមិនខ្លាចនឿយហត់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកសាស្ត្រាចារ្យ **ម៉ាន់ គីមឡេង** ជាសាស្ត្រាចារ្យណែនាំសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើការណែនាំ បង្ហាត់បង្ហាញ ពិនិត្យ កែតម្រូវ និងពន្យល់ទៅលើកិច្ចការសារណានេះតាំងពីដើមរហូតដល់ចប់ ហើយទទួលបានផលជាទីគាប់ចិត្ត។

ជាទីបញ្ចប់ នាងខ្ញុំសូមជូនពរសាធុការជូន **មាតាបិតា ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ និស្សិត** និងក្រុមគ្រួសារឱ្យជួបតែ សេចក្តីសុខ សេចក្តីចម្រើន មានសុខភាពល្អ និងជៀសឆ្ងាយនូវជម្ងឺកាចសាហាវទាំងឡាយ និងជាពិសេសសូមគោរពជូនពរពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេលនៃការសិក្សាបួនឆ្នាំទៅលើផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក៏មកដល់ទីបញ្ចប់ដែលបានផ្តល់ផលជាទីគាប់ចិត្ត។ នៅទីបញ្ចប់នៃការសិក្សានេះ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានផ្តល់ឱកាសឱ្យនាងខ្ញុំរៀបរៀងសារណាឡើងដើម្បីទុកជាស្នាដៃដែលបានសិក្សាអស់រយៈពេល០៤ឆ្នាំមកនេះ។ នៅក្នុងសារណានេះ នាងខ្ញុំបានលើកយកប្រធានបទ **"ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា"** ដែលប្រធានបទនេះជាចំណុចដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់និស្សិតក្នុងការសិក្សា។ នាយកដ្ឋានសុខុមាលភាពសង្គម គឺជានាយកដ្ឋានមួយដែលត្រូវបានបង្កើតឡើងធ្វើការគាំពារសង្គម វាមានតួនាទីសំខាន់ខ្លាំងណាស់នៅក្នុងសង្គមបច្ចុប្បន្ន ប៉ុន្តែមិនសូវជាមានអ្នកចាប់អារម្មណ៍ទៅលើនាយកដ្ឋាននេះឡើយ។

នាងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវនេះ នឹងក្លាយជាប្រយោជន៍ទៅដល់អ្នកនិស្សិតក្នុងការសិក្សាស្វែងយល់អំពីនាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាពិសេសវានឹងក្លាយជាការឆ្លើយតបទៅនឹងសំណួររបស់និស្សិតដែលតែងតែមានការងឿយឆ្ងល់មករហូតថាតើស្ថាប័នណាមានសមត្ថកិច្ចក្នុងការអនុវត្តកិច្ចគាំពារសង្គម? និងជាពិសេសសារណានេះនឹងក្លាយជាប្រទីបទៅដល់និស្សិតក្នុងការសិក្សាអំពីដំណើរការនៃកម្មវិធីនានាដែលត្រូវបានបង្កើតឡើងដោយគោលនយោបាយជាតិគាំពារសង្គមដែលមានដូចជាកម្មវិធីឧបត្ថម្ភជូនជនក្រីក្រដែលផ្ទុកមេរោគកូវីដ-១៩ជាដើម។ ក្នុងសារណានេះនាងខ្ញុំបានព្យាយាមគាងគរនូវបទដ្ឋានផ្សេងៗមកធ្វើការឆ្លុះបញ្ចាំង ដល់និស្សិតអ្នកសិក្សា ឱ្យបានយល់អំពីដំណើរការនីមួយៗ។

នាងខ្ញុំពិតជាមានមោទនភាពណាស់ប្រសិនបើកិច្ចការស្រាវជ្រាវនេះបានផ្តល់ចំណេះដឹងទៅកាន់និស្សិតក្នុងការសិក្សាស្វែងយល់ ទន្ទឹមនឹងនេះនាងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនទៅលើកំហុសដែលកើតឡើងដោយអចេតនា។ ដូចពាក្យគេថា ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច ដូច្នេះនាងខ្ញុំមិនខ្លាចរអានឹងទទួលយកការិះគន់បែបស្ថាបនាពីសំណាក់មិត្តអ្នកអានដើម្បីធ្វើឱ្យសារណានេះមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ០១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ០១

២. ចំណោទបញ្ហានៃការដោះស្រាយ ........ ០២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ០២

៤. ដែនកំណត់នៃការស្រាវជ្រាវ ........ ០២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ០២

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ០៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃនាយកដ្ឋានសុខុមាលភាពសង្គម**

**ផ្នែកទី១៖ អគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា**

១. តួនាទីភារកិច្ច ........ ០៤

១.១. វិស័យសង្គមកិច្ច ........ ០៤

១.២. វិស័យអតីតយុទ្ធជន ........ ០៥

១.៣. វិស័យយុវនីតិសម្បទា ........ ០៦

២. រចនាសម្ព័ន្ធ ........ ០៦

**ផ្នែកទី២៖ គោលបំណង** ........ ០៦

១. រក្សាសុខុមាលភាព ........ ០៧

១.១. សុខុមាលភាពគ្រួសារ ........ ០៧

១.២. សុខុមាលភាពសង្គម ........ ០៧

២. ការផ្តល់ជំនួយ ........ ០៧

**ជំពូកទី២**

**ការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម**

**ផ្នែកទី១៖ ភារកិច្ចរបស់នាយកដ្ឋានសុខុមាលភាពសង្គម** ........ ០៨

១. តួនាទីនៅក្នុងវិស័យគាំពារសង្គម ........ ០៨

២. តួនាទីនៅក្នុងវិស័យគ្រួសារ........................................................................................... ០៩
៣. ជនអនាថា និងចំណាកស្រុក.............................................................................................. ០៩
៤. សង្គ្រោះសង្គម ................................................................................................................ ០៩
៤.១. ការផ្តល់ជំនួយជនរងគ្រោះកម្រិត១ ................................................................................. ១០
៤.២. ការផ្តល់ជំនួយជនរងគ្រោះកម្រិត២.................................................................................. ១០
៤.៣. ការផ្តល់ជំនួយជនរងគ្រោះកម្រិត៣ ................................................................................. ១០
៥. តួនាទីនៅក្នុងវិស័យប្រឆាំងជម្ងឺរាតត្បាត ............................................................................ ១១
**ផ្នែកទី២៖ រចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី** ................................................................ ១១
១. ថ្នាក់ជាតិ .......................................................................................................................... ១១
១.១.ការិយាល័យគ្រប់គ្រងទិន្នន័យ និងទំនាក់ទំនង.................................................................. ១១
១.២.ការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា.............................................................. ១២
១.៣.ការិយាល័យកិច្ចការគ្រួសារ .............................................................................................១៣
១.៤.ការិយាល័យសង្គ្រោះសង្គម ............................................................................................. ១៤
១.៥.ការិយាល័យសេវាផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ........................ ១៤
២. ថ្នាក់ក្រោមជាតិ .............................................................................................................. ១៥
១.១.ការិយាល័យរដ្ឋបាល និងបុគ្គលិក ..................................................................................... ១៥
១.២.ការិយាល័យហិរញ្ញវត្ថុ និងផែនការ .................................................................................. ១៥
១.៣.ការិយាល័យសុខុមាលភាពសង្គម និងជួញដូរមនុស្ស............................................................ ១៦

## ជំពូកទី៣

## សមិទ្ធិផលសម្រេចបានរបស់នាយកដ្ឋានសុខុមាលភាពសង្គម

**ផ្នែកទី១៖ ការធ្វើអង្កេតរហ័សនៃជនអនាថា** ..........................................................................១៧
១. សញ្ញាណនៃការអនុវត្តការធ្វើអង្កេតរហ័ស ...........................................................................១៧
១.១. អ្នកអនុវត្ត .....................................................................................................................១៧
១.២. ជនជាគោលដៅអនុវត្ត .................................................................................................. ១៨
២. គោលបំណង ...................................................................................................................... ១៨
៣. យន្តការនៃការអនុវត្ត........................................................................................................ ១៨

**ផ្នែកទី២៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ......១៩**
១. គោលបំណង ........................................................................................................ ១៩
២. ការពិនិត្យតាមដានអនុវត្ត............................................................................................ ១៩
២.១. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង ..................................................................២០
២.២. ការអនុវត្តលក្ខខណ្ឌ....................................................................................................២១
៣. យន្តការនៃការអនុវត្តកម្មវិធី.........................................................................................២១
៣.១. ក្រសួង ស្ថាប័នថ្នាក់ជាតិ..............................................................................................២១
៣.២. អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ........................................................................ ២៣
៣.៣. ស្ថាប័នបើកផ្តល់............................................................................................................២៥
**ផ្នែកទី៣៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩**..........................................................................................................២៦
១.ដំណើរការនៃកម្មវិធី.........................................................................................................២៦
២.ការត្រួតពិនិត្យលើការអនុវត្តកម្មវិធី.................................................................................២៦
៣.យន្តការដោះស្រាយបណ្តឹងឧបាស្រ័យ...................................................................................២៧
៤.យន្តការការគាំទ្រនៃការអនុវត្តកម្មវិធី ................................................................................២៧
**សេចក្តីសន្និដ្ឋាន**.......................................................................................................... **២៩**
**អនុសាសន៍** ................................................................................................................. **៣១**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសដែលទទួលរងនូវសង្គ្រាមរ៉ាំរ៉ៃជាច្រើនលើកជាច្រើនសារ ដែលសង្គ្រាមនេះបានបន្សល់ទុកនូវសោធនាដកម្មជាច្រើនដូចជា ជនពិការ កុមារកំព្រា ស្ត្រីមេម៉ាយ ចាស់ជរាដែលគ្មានទីពឹង។ ការឆ្លងកាត់សង្គ្រាមនេះ ប្រជាជនមួយចំនួនមិនសូវជាទទួលបានការសិក្សា ជាហេតុធ្វើឱ្យមានភាពល្អក់កករកើតឡើងនៅក្នុងសង្គម ដូចជាអំពើហិង្សាក្នុងគ្រួសារ ការឆ្លងជំងឺកាចសាហាវផ្សេងៗដោយសារកង្វះអនាម័យ ការឆ្លងជំងឺអេដស៍ដោយសារការរួមភេទដោយមិនប្រើប្រាស់ស្រោមអនាម័យជាដើម។ ស្របជាមួយនឹងការមិនសូវមានចំណេះដឹង ក៏មានជនមួយចំនួនដែលរស់នៅដោយមិនមានទីលំនៅ ជនអនាថាដែលរស់នៅតាមចិញ្ចើមផ្លូវ កុមារដែលត្រូវបានបង្ខំឱ្យដើរសុំទាន ដែលត្រូវតែជាជនដែលទទួលរងដោយសារភាពក្រីក្រ។ កន្លងមករាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលមានដំណាក់កាលមួយផ្តោតសំខាន់ពីធនធានមនុស្ស ធ្វើការលើវិស័យចំនួន ០៤ ដែលមានវិស័យទីបួនធ្វើការផ្តោតសំខាន់ទៅលើយេនឌ័រ និងគាំពារសង្គម។ ដើម្បីធ្វើការផ្តោតសំខាន់ទៅលើគាំពារសង្គមនេះ រាជរដ្ឋាភិបាល បានព្យាយាមធ្វើការដាក់ចេញនូវគោលនយោបាយផ្សេងៗដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការចូលរួមផ្តល់ជាសុខុមាលភាពសង្គមជូនប្រជាជន។ នៅក្នុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលជាគោលនយោបានបង្ហាញផ្លូវទៅកាន់ស្ថាប័នអនុវត្តក្នុងការអនុវត្តគោលការណ៍គាំពារសង្គម ដែលក្របខណ្ឌនេះត្រូវបានផ្តោតសំខាន់ទៅលើប្រព័ន្ធជំនួយសង្គម ប្រព័ន្ធសន្តិសុខ និងអភិបាលកិច្ច។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នដែលធ្វើការជាមួយនឹងជនងាយរងគ្រោះ និងជនរងគ្រោះ ដែលមានដូចជាអតីតយុទ្ធជន ជនពិការ កុមារ ស្ត្រី មនុស្សចាស់ ការស្តារសម្បទា ដែលទាំងអស់នេះសុទ្ធសឹងតែជាប្រព័ន្ធនៃកិច្ចគាំពារសង្គម។ នៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺត្រូវបានបែងចែករចនាសម្ព័ន្ធ តាមអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ និងបង្ហាញពីតួនាទីរបស់រចនាសម្ព័ន្ធនីមួយៗស្របទៅតាមប្រភេទជនរងគ្រោះ។ នាយកដ្ឋានសុខុមាលភាពសង្គមជានាយកដ្ឋានមួយ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលធ្វើការជាមួយជនរងគ្រោះដែលគ្មានទីពឹងទាំងជនដែលមានស្មារតីធម្មតា និងជនវិបល្លាស្មារតី យេនឌ័រ ការផ្តល់ជំនួយបឋម ការសង្កេតទៅលើជំងឺកាចសាហាវផ្សេងៗជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នាយកដ្ឋានសុខុមាលភាពសង្គម ជានាយកដ្ឋានមួយដែលធ្វើការផ្ដោតសំខាន់ក្នុងការរក្សាសណ្ដាប់ធ្នាប់សង្គម ភាពសុខដុមក្នុងសង្គម ជាពិសេសការផ្ដល់ភាពកក់ក្ដៅទៅកាន់ជនរងគ្រោះ ដែលបង្ហាញទៅថា ជនទាំងនោះនឹងមិនត្រូវបានគេបោះបង់នោះឡើយ។ ពាក្យថាសុខុមាលភាពសង្គមមួយម៉ាត់គឺមានន័យធំទូលំទូលាយណាស់ ដូច្នេះហើយទើបមានសំណួរជាច្រើនត្រូវបានចោទឡើងមកថា តើនាយកដ្ឋានសុខុមាលភាពសង្គមមានតួនាទីអ្វីខ្លះ? តើនាយដ្ឋានសុខុមាលភាពសង្គមនេះមានដំណើរការយ៉ាងដូចម្ដេច និងរចនាសម្ព័ន្ធអ្វីខ្លះ? តើនាយកដ្ឋាននេះបានសម្រេចបានសមិទ្ធិផលអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺមានគោលបំណងបង្ហាញអ្នកសិក្សាឱ្យបានឃើញ ក៏ដូចជាបានដឹងអំពីនាយកដ្ឋានសុខុមាលភាពសង្គមព្រោះហេតុថានាយកដ្ឋាននេះពុំសូវជាមានអ្នកចាប់អារម្មណ៍នោះឡើយ។ បើកាលណាគ្មានអ្នកចាប់អារម្មណ៍ នោះប្រាកដណាស់កិច្ចការដែលនាយកដ្ឋានកំពុងអនុវត្តនឹងពុំមានអ្នកបានដឹងថាស្ថាប័នណាអ្នកអនុវត្តដូច្នេះក្នុងសារណានេះនឹងនាំមិត្តអ្នកអានបានស្វែងយល់បន្ថែមពីនាយកដ្ឋានសុខុមាលភាពសង្គម ក៏ដូចជាការបង្ហាញអំពីក្របខ័ណ្ឌនយោបាយរាជរដ្ឋាភិបាលក្នុងការយកចិត្តទុកដាក់លើជនរងគ្រោះ និងងាយរងគ្រោះក្នុងសង្គមបច្ចុប្បន្ន។ បន្ថែមពីនេះទៀតសារណានេះមានគោលបំណងបង្ហាញទៅដល់មិត្តអ្នកអានឱ្យបានដឹងថា ប្រភេទជនរងគ្រោះណាគួរតែត្រូវបានទទួលសេវាសង្គមកិច្ចពីសំណាក់ នាយកដ្ឋានសុខុមាលភាពសង្គម ព្រោះបានបញ្ជាក់ហើយថា នៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាននាយកដ្ឋានជាច្រើនដែលមានតួនាទីជាច្រើនផ្សេងៗគ្នាស្របទៅតាមប្រភេទនៃជនរងគ្រោះ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងកិច្ចស្រាវជ្រាវនេះមានទំហំនៃការសិក្សាគឺ ត្រឹមកម្រិតនៃនាយកដ្ឋានសុខុមាលភាពសង្គមប៉ុណ្ណោះគឺនឹងលើកឡើងតែតួនាទីផ្សេងៗដែលនាយកដ្ឋាននេះអនុវត្ត និងមិនមានការលេចធ្លាយដល់តួនាទីរបស់នាយកដ្ឋានផ្សេងឡើយ។ បើទោះបីជាពេលខ្លះ តួនាទីនាយកដ្ឋានមានលាយឡំជាមួយនឹងនាយកដ្ឋានផ្សេងក៏ដោយក៏កិច្ចការនោះគ្រាន់តែជាកិច្ចការចូលរួមសហការប៉ុណ្ណោះ ចំណែកនៅក្នុងសារណានេះនឹងសិក្សាអំពីតួនាទីគោលរបស់នាយកដ្ឋានតែម្ដង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងឡើងដោយសម្រិតសម្រាំង និងជាពិសេសគឺការប្រមូលផ្ដុំនូវឯកសារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយសារណានេះនឹងនាំមិត្តអ្នកអានបានស្គាល់ពីនាយកដ្ឋានសុខុមាលភាពសង្គមឱ្យកាន់តែច្បាស់ ដែលមានអមជាមួយកម្មវិធីផ្សេងៗសង្គមដែលទើបតែកើត

ឡើងនៅក្នុងសង្គមបច្ចុប្បន្ន។ សារណានេះ នឹងនាំមិត្តអ្នកអានបានដឹងថា តើជនរងគ្រោះដែលអ្នករាល់គ្នាបានឃើញរាល់ថ្ងៃពិតជាមិនមានអ្នកខ្វល់ខ្វាយ ឬយ៉ាងណា ព្រោះសារណានេះនឹងបកស្រាយនូវចម្ងល់មិត្តអ្នកអាន។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទនេះ គឺត្រូវបានបែងចែកចេញជា ០៣ជំពូករួមមាន៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃនាយកដ្ឋានសុខុមាលភាពសង្គម**

**ជំពូកទី២៖ ការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម**

**ជំពូកទី៣៖ សមិទ្ធិផលសម្រេចបានរបស់នាយកដ្ឋាន**

ក្នុងជំពូកនីមួយៗនេះ នឹងត្រូវបានបែងចែកចេញជាផ្នែកៗ និងចំណុចៗជាច្រើនទៀតដើម្បីជាភាពងាយស្រួលទៅដល់មិត្តអ្នកអានក្នុងការសិក្សាស្វែងយល់។

# ជំពូកទី១

# សញ្ញាណទូទៅនៃនាយកដ្ឋាន

# សុខុមាលភាពសង្គម

# ជំពូកទី១
# សញ្ញាណទូទៅនៃនាយដ្ឋានសុខុមាលភាពសង្គម

នៅក្នុងជំពូកនេះនឹងធ្វើការសិក្សាទៅលើសញ្ញាណទូទៅ ក៏ដូចជានាំអារម្មណ៍មិត្តអ្នកអានឱ្យបានស្គាល់ពីនាយកដ្ឋាន ជាពិសេសការស្គាល់ពីសាវតា។ នៅក្នុងជំពូកនេះនឹងបង្ហាញមិត្តអ្នកអានចំនួនពីរផ្នែកគឺ **ផ្នែកទី១ អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា** ដែលនឹងបង្ហាញនិស្សិតបានស្គាល់ពីសាវតារបស់នាយកដ្ឋានសុខុមាលភាពសង្គម និង**ផ្នែកទី២ គោលបំណង** នៅក្នុងផ្នែកនេះសិក្សាផ្តោតសំខាន់ទៅលើគោលបំណងក្នុងការបង្កើតនាយកដ្ឋាននេះឡើងមក។

## ផ្នែកទី១៖អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា

អគ្គនាយកដ្ឋានបច្ចេកទេស គឺជាអគ្គនាយកដ្ឋានមួយ[1]នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលដើរតួនាទីជាអគ្គនាយកដ្ឋានដែលអនុវត្តនូវការងារបច្ចេកទេសរបស់ក្រសួងនេះ។ នៅក្នុងចំណុចនេះនឹងធ្វើការបង្ហាញនិស្សិតនូវចំណុចចំនួនពីរគឺ **(១)តួនាទីភារកិច្ច** នៃអគ្គនាយកដ្ឋាននេះ និង**(២)រចនាសម្ព័ន្ធ** ដែលនឹងនាំនិស្សិតឱ្យបានស្គាល់អំពីនាយដ្ឋានដែលជារចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋាននេះ។

### ១. តួនាទីភារកិច្ច

អគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីភារកិច្ចដែលជាបច្ចេកទេសទាំងអស់នៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលធ្វើការផ្តោតសំខាន់ទៅលើវិស័យចំនួនបី[2]គឺ **(១.១)វិស័យសង្គមកិច្ច (១.២)វិស័យអតីតយុទ្ធជន** និង**(១.៣)វិស័យយុវនីតិសម្បទា**។

#### ១.១. វិស័យសង្គមកិច្ច

អគ្គនាយកដ្ឋានបច្ចេកទេសមានតួនាទីធំធេងណាស់ក្នុងវិស័យសង្គមកិច្ច ដែលមានដូចជាការរៀបចំគោលនយោបាយ និងដឹកនាំ ក៏ដូចជាគ្រប់គ្រងរាល់សេវាសង្គមកិច្ចរបស់រដ្ឋ ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ និងប្រជាជនក្រីក្រជាអាទិ៍ លើសពីនេះក៏មានជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គមដែលជួបប្រទះកន្លងមករៀបចំអនុវត្តន៍គោលនយោបាយស្តីពីគ្រួសារ ជនចាស់ជរា រៀបចំលិខិតបទដ្ឋាន និងគ្រប់គ្រងការងារសុំកូនទៅចិញ្ចឹមនៅក្នុង និងក្រៅប្រទេស រៀបចំសេវាសង្គមកិច្ច ដើម្បីថែរក្សា ការពារ និងអប់រំ កុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរ

[1] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខ: ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា៣

[2] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខ: ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា៣

ដោយជំងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល លើសពីនេះក៏មានការរៀបចំគោលការណ៍គាំពារជនពិការ អនុវត្តន៍ការងារស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទទាំងអស់។ សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើពេស្យា ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ លើសពីនេះទៅទៀតក៏មានការសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជួយដល់ជនរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត ម៉្យាងវិញទៀតក៏មានការសហការជាមួយស្ថាប័ន និងអង្គការពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមារ។ គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការដែលលោកមានការលះបង់គ្រប់យ៉ាងដើម្បីមាតុភូមិរបស់យើងគ្រប់គ្នា ហើយការដែលធ្វើបែបនេះគឺយើងបានផ្អែកតាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញភារកិច្ច លើសពីនេះទៅទៀតក៏មានការគ្រប់គ្រងរបបធានារ៉ាប់រងសង្គមដល់កូនកំព្រាពីសពមន្ត្រីរាជការផងដែរ។ ការដឹកនាំការគ្រប់គ្រង និងសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ច ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំ និងការផ្តល់សេវាសង្គមកិច្ចនានា លើសពីនេះយើងក៏មានការបំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានាដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ។

### **១.២. វិស័យអតីតយុទ្ធជន**

នៅក្នុងវិស័យនេះ អគ្គនាយកដ្ឋានបច្ចេកទេសក៏ត្រូវរៀបចំដាក់ឱ្យដំណើរការសម្របសម្រួលគោលនយោបាយជាតិ ស្តីពី អតីតយុទ្ធជន ហើយក៏មានការរៀបចំបញ្ចូលអតីតយុទ្ធជន និងគ្រួសារទៅក្នុងសហគមន៍ដោយមានការលើកកម្ពស់ស្ថានភាពរស់នៅឲ្យបានល្អប្រសើរ និងគ្មានការរើសអើងនៅតាមសហគមន៍សាធារណៈ ដោយការធ្វើបែបនេះគឺយើងបានបង្រៀនគាត់តាមរយៈការបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើ និងបង្កើតមុខរបរផ្សេងៗទៀត។ ការលើកគោលការណ៍អប់រំណែនាំអតីតយុទ្ធជន ឱ្យយល់ពីតម្លៃកាតព្វកិច្ចតួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គម ដើម្បីទទួលបានការអភិវឌ្ឍ ចំណែកឯការគ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ តាមការកំណត់របស់ច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។ ការគ្រប់គ្រង និងដោះស្រាយគោលនយោបាយជូនជនពលីមរណៈ បង្កឱ្យស្លាប់ បាត់ខ្លួន ពិការ និងគ្រួសារនៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពលដែលបាន

បូជាជីវិតដើម្បីប្រទេសជាតិ ហើយយើងក៏មានការលើកកម្ពស់ក៏ដូចជាលើកទឹកចិត្តក្នុងគ្រួសាររបស់ប្រជាពលរដ្ឋដែលលោកជួបការលំបាកដោយសារសមាជិកគ្រួសាររបស់ខ្លួនបានបាត់បង់នូវជីវិតផងដែរ។[3]

### ១.៣. វិស័យយុវនីតិសម្បទា

គ្រប់គ្រងក្មេងពីអាយុ ៧ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខក៏ដូចជាបទល្មើសផ្សេងៗទៀតទូទាំងប្រទេស និងមានតួនាទីក្នុងការកែប្រែ អប់រំ ដើម្បីឱ្យក្មេងៗដែលបានប្រព្រឹត្តបទល្មើសនោះក្លាយទៅជាពលរដ្ឋល្អឡើងវិញ លើសពីនេះយើងក៏មានការបង្កើតមណ្ឌលទទួលអប់រំកុមារតាមការចាំបាច់ ដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្ដុះបណ្ដាលឡើងវិញ ហើយការដែលយើងធ្វើបែបនេះគឺយើងមានការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអង្គការអន្តរជាតិ ដើម្បីបង្កើតកម្មវិធីអប់រំ បណ្ដុះបណ្ដាលអនីតិជនឱ្យបានល្អ ហើយការសហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ទណ្ឌិតតាមពន្ធនាគារ កសាងច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា លើសពីនេះទៅទៀតក៏មានការបង្កើត និងគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងសមាហរណកម្មជនរងគ្រោះទាំងអស់នោះឲ្យទៅក្នុងសហគមន៍វិញ។[4]

## ២. រចនាសម្ព័ន្ធ

នាយកដ្ឋានសុខុមាលភាពសង្គម គឺជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកទេស ដែលមានតួនាទីក្នុងការធ្វើបទដ្ឋានគតិយុត្តផ្សេងៗ និងធ្វើកិច្ចការផ្សេងៗដែលអគ្គនាយកដ្ឋានបានប្រគល់ជូន។ អគ្គនាយកដ្ឋានបច្ចេកទេស គឺមាននាយកដ្ឋាន ០៦ផ្សេងទៀតជាសេនាធិការដែលមានតួនាទីក្នុងការអនុវត្តនូវតួនាទីស្របទៅតាមវិស័យដែលបានលើកឡើងខាងលើ ដែលនាយកដ្ឋានទាំងនោះមានដូចជា នាយកដ្ឋានសុខុមាលភាពពិការ នាយកដ្ឋានយុវនីតិសម្បទា នាយកដ្ឋានអតីតយុទ្ធជន នាយកដ្ឋានសុខុមាលភាពកុមារ នាយកដ្ឋានសុខុមាលភាពមនុស្សចាស់ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។[5]

# ផ្នែកទី២៖ គោលបំណង

សុខុមាលភាពសង្គម គឺជាចំណុចដែលសំខាន់សម្រាប់រាជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេស កាលបើប្រទេសមានសន្តិសុខ មានប្រព័ន្ធគាំពារសង្គមរឹងមាំ មានសណ្ដាប់ធ្នាប់ នោះជាការបង្ហាញឱ្យឃើញពីភាពរីកចម្រើនមួយផ្នែក។ ប្រជាជនកម្ពុជាសព្វថ្ងៃហាក់បីដូចជាបានបោះបង់នូវវប្បធម៌ជួយយកអាសារគ្នា ដូច្នេះ

---

[3] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខ: ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា៣

[4] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខ: ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា៣

[5] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខ: ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា៣

រាជរដ្ឋាភិបាលត្រូវបង្កើតនូវប្រព័ន្ធសន្តិសុខសង្គម ប្រព័ន្ធគាំពារសង្គម ដែលផ្តល់ទៅដល់ជនដែលមិនមានទីពឹង ជនដែលងាយរងគ្រោះជាដើម ហើយនាយដ្ឋានសុខុមាលភាពសង្គមត្រូវបានបង្កើតឡើងក្នុងគោលបំណង **(១)រក្សាសុខុមាលភាព** និង**(២)ការផ្តល់ជំនួយ**។

### ១. រក្សាសុខុមាលភាព

រក្សាសុខុមាលភាព គឺជាការរក្សាភាពសុខដុមរម្យនា ដែលការរក្សាសុខុមាលភាពនេះផ្តោតសំខាន់ទៅលើពីរចំណុចគឺ **(១.១) សុខុមាលភាពគ្រួសារ** និង**(១.២) សុខុមាលភាពសង្គម**។[6]

### ១.១.សុខុមាលភាពគ្រួសារ

គ្រួសារ គឺជាកោសិកានៃសង្គមកាលបើក្នុងគ្រួសារនីមួយៗទទួលបានសុខុមាលភាពនោះសង្គមក៏ទទួលបានភាពរីកចម្រើនដូចគ្នា។ នាយកដ្ឋានសុខុមាលភាពសង្គម បានអនុវត្តនូវកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារដែលធ្វើការបំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងបានដាក់ផែនការសកម្មភាពដែលផ្តោតសំខាន់ទៅលើកិច្ចការគ្រួសារក្នុងឆ្នាំ២០១៩-២០២៣ ដោយធ្វើការអនុវត្តកម្មវិធីគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន និងជាពិសេសការលើកទឹកចិត្តស្ត្រីក្នុងគ្រួសារ និងការបញ្ជ្រាបយេនឌ័រ[7]។

### ១.២. សុខុមាលភាពសង្គម

គោលបំណងរបស់នាយកដ្ឋាន គឺធ្វើយ៉ាងណាឱ្យសង្គមមានភាពសុខដុម អ្វីដែលសំខាន់គឺជនងាយរងគ្រោះ និងជនរងគ្រោះដែលត្រូវតែទទួលបានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល។ ដើម្បីធ្វើការពិនិត្យ និងផ្តល់សេវាសង្គមកិច្ចទៅលើជនទាំងនោះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម[8] ដែលនាយកដ្ឋានត្រូវមានតួនាទីអនុវត្តស្របទៅតាមគោលនយោបាយនោះ[9]។ ជនងាយរងគ្រោះ និងងាយរងគ្រោះនៅទីនេះគឺសម្តៅទៅដល់ ជនអនាថា ជនវិកលចរិត ជនរងគ្រោះដោយគ្រោះមហន្តរាយ ជនផ្ទុកមេរោគអេដស៍ ជំងឺកាចសាហាវ និងជនចំណាកស្រុក[10]។

### ២. ការផ្តល់ជំនួយ

នាយកដ្ឋានសុខុមាលភាពសង្គម មានគោលបំណងក្នុងការផ្តល់ជំនួយទៅដល់ជនងាយរងគ្រោះ និងជនរងគ្រោះនូវជំនួយទាំងចំណេះដឹង និងជំនួយជាការឧបត្ថម្ភ។ ជំនួយចំណេះដឹងសំដៅដល់ការផ្តល់ចំណេះដឹងទូទៅទៅដល់ជនដែលត្រូវទទួលបានចំណេះដឹង តួយ៉ាងការពន្យល់ទៅដល់ប្រជាជនទាក់ទងទៅនឹងជំងឺអេដស៍

---

[6] ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

[7] ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

[8] សៀវភៅក្របខ័ណ្ឌគោលនយោបាយគាំពារសង្គម២០១៦-២០២៥ ចេញដោយរាជរដ្ឋាភិបាលនៅសម័យប្រជុំពេញអង្គ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

[9] ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

[10] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខៈ ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា១៤

និងចំណេះដឹងផ្សេងៗទៀត។ ចំពោះជំនួយជាការឧបត្ថម្ភសម្ភៅទៅដល់ ការផ្តល់ជំនួយជាថវិកា សម្ភារៈ ម្ហូបចំណី និងផ្តល់ការស្នាក់នៅទៅដល់ជនអនាថា ជនរងគ្រោះដោយសារគ្រោះធម្មជាតិ និងគ្រួសារក្រីក្រដែលមានជីវភាពខ្វះខាត។ ក្នុងការផ្តល់ជំនួយនេះ នាយកដ្ឋានសុខុមាលភាពសង្គមក៏បានគាំងគរអង្គការជំនាញនានាក្នុងការធ្វើកិច្ចសហការដើម្បីជាការផ្តល់ជំនួយទៅកាន់ជនរងគ្រោះផងដែរ។ ការធ្វើកិច្ចសហការនេះ នាយកដ្ឋានក៏ត្រូវមានការចុះត្រួតពិនិត្យតាមដានជានិច្ច និងតម្រូវឱ្យអង្គការធ្វើជារបាយការណ៍ជូននាយកដ្ឋានជារៀងរាល់ខែត្រីមាស ឆមាស។

# ជំពូកទី២

# ការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានសុខុមាលភាពសង្គម

# ជំពូកទី២
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខុមាលភាពសង្គម

នាយកដ្ឋានសុខុមាលភាពសង្គម ជានាយកដ្ឋានមួយដែលមានតួនាទីធំធេងណាស់ ជាពិសេសការងារផ្ទាល់ជាមួយជនងាយរងគ្រោះ ហើយនាយកដ្ឋាននេះអាចមានដំណើរការបាន គឺត្រូវការសេនាធិការជាចាំបាច់។ ដូច្នេះនៅក្នុងជំពូកនេះនឹងធ្វើការសិក្សាទៅលើ ០២ចំនុចដាច់ដោយឡែកពីគ្នា គឺ**ភារកិច្ចរបស់នាយកដ្ឋានសុខុមាលភាពសង្គម** និង**តួនាទី របស់រចនាសម្ព័ន្ធនៃនាយកដ្ឋាននេះ**។

## ផ្នែកទី១៖ ភារកិច្ចរបស់នាយកដ្ឋានសុខុមាលភាពសង្គម

នាយកដ្ឋានសុខុមាលភាពសង្គម គឺមានតួនាទីធំធេងណាស់នៅក្នុងសង្គមជាពិសេសរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងសង្គម ដែលនៅក្នុងចំណុចនេះនឹងធ្វើការបង្ហាញនិស្សិតអ្នកអាននូវតួនាទីរបស់នាយកដ្ឋានដែលមានដូចជា (១) **តួនាទីនៅក្នុងវិស័យគាំពារសង្គម** (២)**តួនាទីនៅក្នុងវិស័យគ្រួសារ** (៣)**ជនអនាថា និងចំណាកស្រុក** (៤)**សង្គ្រោះសង្គម** និង(៥)**តួនាទីនៅក្នុងវិស័យប្រឆាំងជម្ងឺរាតត្បាត**។

### ១. តួនាទីនៅក្នុងវិស័យគាំពារសង្គម

កិច្ចគាំពារសង្គម គឺជាតួនាទីចម្បងរបស់រាជរដ្ឋាភិបាល ដែលរួមបញ្ចូលទាំងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយការអនុវត្តទៅលើវិស័យនេះគឺនាយកដ្ឋានសុខុមាលភាពសង្គម។ កិច្ចគាំពារសង្គម គឺជាគោលនយោបាយ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៧ ដែលគោលនយោបាយនេះត្រូវបានផ្តោតសំខាន់ទៅលើពីរ(០២)ចំណុច គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធជំនួយសង្គម គឺជាចំណុចដែលនឹងលើកបង្ហាញនិស្សិតឱ្យបានយល់ច្បាស់ ដោយភ្ជាប់ជាមួយនឹងតួនាទីនាយកដ្ឋាន។ ដោយឡែក ប្រព័ន្ធសន្តិសុខសង្គម គឺជាតួនាទីដោយឡែក ដែលមិនបានរួមបញ្ចូលនាយកដ្ឋានសុខុមាលភាពសង្គមឡើយដោយហេតុថាប្រព័ន្ធសន្តិសុខសង្គម គឺផ្តោតសំខាន់ទៅលើ បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងមូលនិធិជនពិការ។[11]

នាយកដ្ឋានសុខុមាលភាពសង្គម មានតួនាទីក្នុងការបំពេញកាតព្វកិច្ចទៅតាមចំណាត់ការរបស់ក្រសួងជាពិសេសការ ដែលធ្វើការផ្តោតទៅលើការផ្តល់ជំនួយជូនជនក្រីក្រ រៀបចំផែនការសកម្មភាព និងកម្មវិធីជួយសង្គ្រោះដល់ក្រុមជនក្រីក្រងាយរងគ្រោះ និងជួបការលំបាកជាងគេបំផុតនៅក្នុងសង្គម ដើម្បីទប់ស្កាត់ទុរគតភាព និងជាពិសេសការឆ្លើយទៅនឹងគ្រោះមហន្តរាយ ការបណ្តុះបណ្តាលធនធានមនុស្ស(ផ្តោតសំខាន់ទៅលើស្ត្រីមានផ្ទៃពោះ និងកុមារ)។

[11] សៀវភៅក្របខ័ណ្ឌគោលនយោបាយគាំពារសង្គម២០១៦-២០២៥ ចេញដោយរាជរដ្ឋាភិបាលនៅសម័យប្រជុំពេញអង្គ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

### ២. តួនាទីនៅក្នុងវិស័យគ្រួសារ

នាយកដ្ឋាននេះក៏មានតួនាទីចម្បងក្នុងការអនុវត្តក្នុងវិស័យសុខុមាលភាពគ្រួសារ ដោយប្រារព្ធទិវាគ្រួសារ រៀងរាល់ថ្ងៃទី១៥ ខែឧសភា រៀងរាល់ឆ្នាំ។ ដែលមានគោលបំណង និងទិសដៅជម្រុញ និងលើកទឹកចិត្តដល់សកម្មភាពពាក់ព័ន្ធនឹងគ្រួសារ[12]។ នាយកដ្ឋានត្រូវធ្វើការតាមដាន និងវាយតម្លៃកម្មវិធីទាក់ទងជាមួយនឹងការអនុវត្តគោលនយោបាយគ្រួសារ និងជាពិសេសត្រូវធ្វើការស្រាវជ្រាវ ទាំងប្រយោល និងដោយផ្ទាល់អំពីបញ្ហាទាក់ទងគ្រួសារ រួចត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល[13]។ នាយកដ្ឋានសុខុមាលភាពសង្គមក៏បានធ្វើការសហការជាមួយនឹងក្រសួងកិច្ចការនារីក្នុងការអនុវត្តនូវ ផែនការបញ្ច្រាបយេនឌ័រ និងការចិញ្ចឹមកូនបែបវិជ្ជមានផងដែរ។

### ៣. ជនអនាថា និងចំណាកស្រុក

ជនអនាថា គឺសម្ដៅទៅជំពូកជនដែលទីទ័លក្រ ដែលគ្មានទីជម្រក តែលតោល គ្មានទីពឹង[14]។ នាយកដ្ឋានជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ដែលគណៈកម្មាធិការនេះមានតួនាទីក្នុងការដោះស្រាយបញ្ហាជនអនាថាទូទាំងប្រទេសតាមរយៈ ការស្តារនីតិសម្បទា ជនអានាថា និងធ្វើការទប់ស្កាត់ការវិលត្រលប់មកសុំទានវិញ ព្រមទាំងបានផ្តល់សេវាស្នាក់នៅរួមបញ្ចូលទាំង ការថែរទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី[15]។ ជនអនាថាដែលត្រូវបានកំណត់យកមកជាគោលដៅដើម្បីធ្វើការផ្តល់ជំនួយនៅក្នុងនាយកដ្ឋានសុខុមាលភាពសង្គម មានដូចជា ជនចាស់ជរា និងជនពិការដែលគ្មានទីពឹង ជនអនាថា ជនវិកលចរិត ទុរគតជន អ្នកប្រើប្រាស់គ្រឿងញៀន ជនរងគ្រោះ និងងាយរងគ្រោះផ្សេងទៀត[16]។

ចំពោះការធ្វើចំណាកស្រុកវិញ នាយកដ្ឋានបានដាក់ចេញនូវសៀវភៅមេរៀនចំណាកស្រុក ដែលមានគោលបំណងក្នុងការការពារការធ្វើចំណាកស្រុកដែលគ្មានសុវត្ថិភាព។ នាយកដ្ឋានសុខុមាលភាពសង្គមត្រូវធ្វើការត្រួតពិនិត្យទៅលើការធ្វើចំណាកស្រុក ជាពិសេសការចំណាកស្រុកដែលអាចនាំឱ្យមានការជួញដូរផ្លូវភេទលើកុមារ និងស្ត្រី និងត្រូវធ្វើការផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដែលប្រកបទៅដោយសុវត្ថិភាពទៅកាន់ជនទូទៅជាចំណេះដឹងមូលដ្ឋាន។[17]

---

[12] អនុក្រឹត្យស្តីពីទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា, លេខ៤៩.អនក្រ.បក ,ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥, មាត្រា១

[13] អនុក្រឹត្យស្តីពីទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា, លេខ៤៩.អនក្រ.បក ,ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥, មាត្រា២

[14] អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា, លេខ១២៩អនក្រ.បក ,ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥,មាត្រា២

[15] អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា, លេខ១២៩អនក្រ.បក ,ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥,មាត្រា៧

[16] សៀវភៅកម្រងព័ត៌មានសេវាសារធារណៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

[17] សៀវភៅស្តីពីការចំណាកស្រុកប្រកបដោយ សុវត្ថិភាព ឆ្នាំ២០១៩

## ៤. សង្គ្រោះសង្គម

នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានកាតព្វកិច្ចក្នុងការផ្តល់ជាជំនួយសង្គ្រោះបឋមទៅកាន់ ជនរងគ្រោះ ដោយសារគ្រោះធម្មជាតិ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែលសរសេរជាអក្សរកាត់ថា **គ.ជ.គ.ម.** ជាសេនាធិការឱ្យរាជរដ្ឋាភិបាលដើម្បីដឹកនាំគ្រប់គ្រង និងសម្រួលការងារគ្រប់គ្រងគ្រោះមហន្តរាយដែលបង្ករឡើងដោយធម្មជាតិឬមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា[18]។ ព្រមទាំងធ្វើការអង្កេតទៅលើការផ្តល់ជាជំនួយសង្គ្រោះបឋម (ជំនួយសង្គ្រោះបឋម គឺជាជំនួយដែលអាចផ្តល់ឱ្យបានភ្លាមៗ ដូចជា ស្បៀងអាហារ សម្លៀកបំពាក់ និងការជួយរកជម្រកសុវត្ថិភាព) ដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយ។ ការផ្តល់ជំនួយនៅក្នុងនាយកដ្ឋានត្រូវបានបែងចែកចេញជា ០៣ **គឺ (៤.១) ការផ្តល់ជំនួយជនរងគ្រោះកម្រិត១ (៤.២) ការផ្តល់ជំនួយជនរងគ្រោះកម្រិត២** និង(៤.៣) **ការផ្តល់ជំនួយជនរងគ្រោះកម្រិត៣**។

### ៤.១. ការផ្តល់ជំនួយជនរងគ្រោះកម្រិត១

ប្រជាជនដែលត្រូវបានកំណត់ថាជាជនរងគ្រោះកម្រិត១(កម្រិតធ្ងន់) ដរាបណាជាប្រជាជនរងគ្រោះទីទ័លក្រដាច់ស្បៀង គ្មានមុខរបរ គ្មានដីធ្លីដាំដុះ មេគ្រួសារជាស្ត្រីមេម៉ាយកូនច្រើន មានគ្រួសារជនពិការ ចាស់ជរាមានជំងឺរ៉ាំរ៉ៃពុំមានលទ្ធភាពឱ្យកូនទៅសិក្សា។ ចំពោះប្រជាជនប្រភេទនេះត្រូវផ្តល់ជំនួយជា០២ជំហានគឺះ

**ជំហានទី១៖** ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពី ៥០០.០០០រក្នុងមួយគ្រួសារ និងផ្តល់ថវិកាជាក់ស្តែងដើម្បីទិញស្បៀងអាហារ និងសម្ភារ អង្ករ អំបិល មី មុង ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។

**ជំហានទី២៖** ត្រូវផ្តល់ជំនួយគាំទ្រសម្រាប់ការស្តារនីតិសម្បទា ដើម្បីជនរងគ្រោះមានស្ថិរភាពស្បៀងអាហារសម្រាប់ជីវភាពប្រចាំថ្ងៃក្នុងរយៈពេល ៣០ថ្ងៃ និងផ្តល់សម្ភារសម្រាប់ជួសជុលផ្ទះ ឬសាងសង់ជម្រកស្នាក់នៅបណ្តោះអាសន្នដែលមិនលើសពីចំនួន ១.៥០០.០០០រ ក្នុងមួយគ្រួសារ។[19]

### ៤.២. ការផ្តល់ជំនួយជនរងគ្រោះកម្រិត២

ប្រជាជនដែលត្រូវបានកំណត់ថាជាប្រជាជនរងគ្រោះកម្រិត២(កម្រិតមធ្យម) ជាជនទីទ័លក្រ ដាច់ស្បៀងខូចខាតបាត់បង់ទ្រព្យសម្បត្តិផ្ទះសម្បែង ប៉ះពាល់មុខរបរ ឬសុខភាព និងខូចខាតផលដំណាំ។ល។ ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ត្រូវជាសម្ភារប្រើប្រាស់ ស្បៀងអាហារ និងថវិកាមិនលើសពី៣០០.០០០រ ក្នុងមួយគ្រួសារ

[18] ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, លេខ នស/រកត/១២១៥/១១៤១, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១

[19] សៀវភៅកម្រងព័ត៌មានសេវាសារធារណៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ សម្ភារៈរួមមានៈ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។[20]

**៤.៣. ការផ្តល់ជំនួយជនរងគ្រោះកម្រិត៣**

ប្រជាជនដែលត្រូវបានកំណត់ថាជាប្រជាជនរងគ្រោះកម្រិត៣(កម្រិតស្រាល) ជាជនដែលទទួលរងផលខូចខាតទ្រព្យសម្បត្តិ ឬផលដំណាំតិចតួច។ ការផ្តល់ជំនួយត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ជា សម្ភារៈប្រើប្រាស់ ស្បៀងអាហារ និងថវិកាមិនឱ្យលើសពី ២០០.០០០រ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាតាមជាក់ស្តែងដើម្បីទិញស្បៀងអាហារ និងសម្ភាររួមមានៈ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។

**៥. តួនាទីនៅក្នុងវិស័យប្រឆាំងជម្ងឺរាតត្បាត**

នាយកដ្ឋានសុខុមាលភាពសង្គម មានភារកិច្ចក្នុងការទប់ស្កាត់នូវជំងឺកាចសាហាវដែលត្រូវផ្តោតសំខាន់ទៅលើជំងឺអេដស៍ និងមេរោគកាចសាហាវផ្សេងៗ[21] ព្រមទាំងជួយជនរងគ្រោះ និងជនដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទទួលបាននូវសេវាថែទាំ និងគាំទ្រប្រកបដោយសុវត្ថិភាព។ តួយ៉ាង នាយកដ្ឋានសុខុមាលភាពសង្គម គឺជាសេនាធិការនៃអាជ្ញាធរអេសដ៍ប្រចាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលធ្វើការអង្កេតទៅលើជម្ងឺអេសដ៍ ក៏ដូចជាការសិក្សាទៅលើបញ្ហាជម្ងឺកាចសាហាវផ្សេងៗ ដែលបច្ចុប្បន្ន នាយកដ្ឋានសុខុមាលភាពសង្គមក៏មានតួនាទីក្នុងការពិនិត្យទៅលើជនដែលមានផ្ទុកមេរោគកូវីដ១៩ដែលមានជីវភាពក្រីក្រផងដែរ។[22]

**ផ្នែកទី២៖ រចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី**

រាល់កិច្ចការងាររបស់នាយកដ្ឋានសុខុមាលភាពសង្គមត្រូវមានសេនាធិការអមទៅតាមតួនាទីដែលខ្លួនត្រូវអនុវត្តទៅតាមវិស័យនីមួយៗដែលបានសិក្សាខាងលើ។ នៅក្នុងចំណុចនេះនឹងធ្វើការសិក្សាទៅលើ សេនាធិការ **(១)ថ្នាក់ជាតិ** និង**(២)ថ្នាក់ក្រោមជាតិ**។

**១. ថ្នាក់ជាតិ**

នៅថ្នាក់ជាតិ នាយកដ្ឋានសុខុមាលភាពសង្គមត្រូវបានបែងចែកជា ០៥ការិយាល័យផ្សេងៗគ្នា ដែលអនុវត្តនូវតួនាទីផ្សេងៗគ្នាស្របទៅតាមវិស័យគោលដែលនាយកដ្ឋានអនុវត្ត ដែលការិយាល័យទាំងនោះមានដូចជា **(១.១) ការិយាល័យគ្រប់គ្រងទិន្នន័យ និងទំនាក់ទំនង (១.២) ការិយាល័យសេវាទប់ស្កាត់ និងការពារជន**

[20] សៀវភៅកម្រងព័ត៌មានសេវាសាធារណៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

[21] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា, លេខៈ ៥៤.អនក្រ.បក,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ មាត្រា១៤

[22] សៀវភៅកម្រងព័ត៌មានសេវាសាធារណៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

**អនាថា (១.៣) ការិយាល័យកិច្ចការគ្រួសារ (១.៤) ការិយាល័យសង្គ្រោះសង្គម និង(១.៥) ការិយាល័យសេវាផ្តុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ។**

**១.១. ការិយាល័យគ្រប់គ្រងទិន្នន័យ និងទំនាក់ទំនង**

ការិយាល័យនេះ អាចហៅមួយបែបទៀតបានថា ការិយាល័យរដ្ឋបាល ដោយហេតុថាការិយាល័យនេះ មានតួនាទីចម្បងទៅលើការងាររដ្ឋបាលរបស់នាយកដ្ឋាន ដែលតួនាទីទាំងនោះមានដូចជា៖

- ទទួលខុសត្រូវការងាររបៀបរៀបរយរបស់នាយកដ្ឋាន
- គ្រប់គ្រងលិខិតចេញ-ចូលការងារសណ្តាប់ធ្នាប់របស់នាយកដ្ឋាន
- គ្រប់គ្រងស្ថិតិមន្ត្រីរាជការរបស់នាយកដ្ឋាន
- រៀបចំផែនការក្របខណ្ឌរបស់នាយកដ្ឋាន
- រៀបចំតារាងវត្តមានសម្រាប់ចុះឈ្មោះមន្ត្រីមកធ្វើការ
- រៀបចំ អនុវត្តន៍ផែនការបណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រីពាក់ព័ន្ធ
- រៀបចំគម្រោង កៀរគរប្រភពធនធាន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស
- គ្រប់គ្រងសម្ភារៈការិយាល័យ និងរៀបចំបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន
- ជាសេនាធិការឲ្យនាយកដ្ឋានរាល់កិច្ចប្រជុំ
- រៀបចំ និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធផ្សេងៗទៀតស្របតាមមុខងាររបស់នាយកដ្ឋាន
- រៀបចំធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ របស់ការិយាល័យ របស់នាយកដ្ឋាន
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានប្រគល់ជូន។[23]

**១.២. ការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា**

ការិយាល័យនេះ មានតួនាទីផ្តោតសំខាន់ទៅលើជនអានាថា គឺត្រូវធ្វើការគៀងគងជនអានាថា និងសមាហរណកម្ម ជនអនាថានោះដែលត្រូវធ្វើសកម្មភាពដូចជា៖

- រៀបចំ និងអនុវត្តន៍គោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា
- បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មការជាតិដោះស្រាយបញ្ហាជនអនាថា

[23]ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតនៅក្រោមនាយកដ្ឋានសុខុមាលភាពសង្គម, លេខ ២២៤៩ ស.អ.យ., ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ប្រការ៣ កថាខណ្ឌ១

- រៀបចំ និងអនុវត្តន៍លិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនអនាថា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសហគមន៍ក្នុងការផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា
- រៀបចំ និងអនុវត្តន៍កម្មវិធីផ្តល់សេវាទប់ស្កាត់ការហូរចូលជនអនាថា មកកាន់ទីក្រុង ទីប្រជុំជន
- រៀបចំគម្រោងកៀងគរ ស្វែងរកធនធានសម្រាប់ការងារសេវាទប់ស្កាត់ និងការពារជនអនាថា
- តាមដាន ត្រួតពិនិត្យ វាយតម្លៃគម្រោងកម្មវិធី ដែលមានការពាក់ព័ន្ធទៅនឹងការផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា
- រៀបចំធ្វើរបាយការណ៍បូកសរុបសកម្មភាពប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំខែរបស់ការិយាល័យ
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានប្រគល់ជូន។[24]

### ១.៣. ការិយាល័យកិច្ចការគ្រួសារ

ការិយាល័យនេះ ផ្តោតសំខាន់ទៅលើកិច្ចការគ្រួសារនៅក្នុងសង្គម ដែលមានដូចជា ការបង្ការអំពើហិង្សានៅក្នុងគ្រួសារ និងសកម្មភាពផ្សេងៗទៀតដូចជា ៖

- រៀបចំ និងអនុវត្តន៍គោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងកិច្ចការគ្រួសារ។
- រៀបចំ និងអនុវត្តន៍គម្រោងអភិវឌ្ឍន៍សហគមន៍ ការដោះស្រាយបញ្ហានៅមូលដ្ឋាន សម្បទាសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រ
- រៀបចំ និងអនុវត្តន៍បទដ្ឋានស្តីពី លក្ខណៈវិនិច្ឆ័យសម្រាប់ប្រជាជនក្រីក្រ
- រៀបចំទិវាអន្តរជាតិស្តីពី គ្រួសារ ១៥ ឧសភា
- រៀបចំ និងអនុវត្តន៍ចលនាគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសហគមន៍ក្នុងការផ្តល់សេវាកិច្ចការគ្រួសារ
- រៀបចំគម្រោងកៀងគរ ស្វែងរកធនធានសម្រាប់កិច្ចការគ្រួសារ
- បំពេញមុខងារជាលេខាធិការដ្ឋានរបស់ក្រុមការងារយេនឌ័រ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

[24] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតនៅក្រោមនាយកដ្ឋានសុខុមាលភាពសង្គម, លេខ ២២៤៩ ស.អ.យ., ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ប្រការ៣ កថាខណ្ឌ២

- តាមដាន និងវាយតម្លៃគម្រោងកម្មវិធីនានា ដែលមានការពាក់ព័ន្ធទៅនឹងការផ្តល់សេវាកិច្ចការគ្រួសារ
- រៀបចំធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។[25]

**១.៤. ការិយាល័យសង្គ្រោះសង្គម**

ការិយាល័យនេះ ផ្តោតសំខាន់ទៅលើគ្រួសារដែលជួបគ្រោះធម្មជាតិ និងផ្តល់ជំនួយសង្គ្រោះបន្ទាន់នានាដែលកើតមានឡើងដោយយថាហេតុ និងសកម្មភាពផ្សេងទៀតដូចជា៖

- រៀបចំ និងអនុវត្តន៍គោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការងារសង្គ្រោះសង្គមសម្រាប់ប្រជាជនរងគ្រោះដោយសារគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ និងប្រជាជនក្រីក្រងាយរងគ្រោះនៅក្នុងសង្គម
- រៀបចំ និងអនុវត្តន៍គម្រោងជំនួយសង្គ្រោះសង្គមបន្ទាន់ នៅពេលមានហេតុការណ៍អ្វីកើតឡើង
- រៀបចំ និងអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលការងារសង្គ្រោះសង្គម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសហគមន៍ក្នុងការផ្តល់ជំនួយសង្គ្រោះសង្គមបន្ទាន់
- រៀបចំគម្រោងកៀងគរ ស្វែងរកធនធានសម្រាប់ការងារសង្គ្រោះសង្គម
- ពិនិត្យ និងផ្តល់យោបល់លើសំណើពាក់ព័ន្ធការសុំជំនួយសង្គ្រោះបន្ទាន់ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ។
- រៀបចំធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។[26]

**១.៥. ការិយាល័យសេវាផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ**

មានតួនាទីជាច្រើនដូចជា ៖

- រៀបចំ និងអនុវត្តន៍គោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន គម្រោងកម្មវិធី និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទៀត
- បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មការការពារទប់ស្កាត់មេរោគអេដស៍ ជំងឺអេដស៍ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

[25]ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតនៅក្រោមនាយកដ្ឋានសុខុមាលភាពសង្គម, លេខ ២២៤៩ ស.អ.យ., ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ប្រការ៣ កថាខណ្ឌ៥

[26]ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតនៅក្រោមនាយកដ្ឋានសុខុមាលភាពសង្គម, លេខ ២២៤៩ ស.អ.យ., ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ប្រការ៣ កថាខណ្ឌ៤

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសហគមន៍ក្នុងការផ្តល់សេវាការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទៀត
- រៀបចំ និងអនុវត្តន៍គម្រោងជំនួយឧបត្ថម្ភជនរងគ្រោះដោយមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទៀត
- រៀបចំគម្រោងកៀងគរស្វែងរកធនធានសម្រាប់ការងារសេវាទប់ស្កាត់ ការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- រៀបចំធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានបានប្រគល់ជូន។[27]

**២. ថ្នាក់ក្រោមជាតិ**

នៅថ្នាក់ក្រោមជាតិរបស់នាយកដ្ឋានសុខុមាលភាពសង្គម គឺមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ដែលនៅក្នុងមន្ទីរនេះ មាន ការិយាល័យចំនួន ១២ជាសេនាធិការ[28]។ ដោយឡែកនៅក្នុងចំណោមការិយាល័យចំនួន ១២នេះ នៅក្នុងកិច្ចស្រាវជ្រាវនេះនឹងលើកឡើងតែការិយាល័យចំនួន ០៣ប៉ុណ្ណោះដែលធ្វើការពាក់ព័ន្ធជាមួយនឹងនាយកដ្ឋានសុខុមាលភាពសង្គមគឺ (១.១)ការិយាល័យរដ្ឋបាល និងបុគ្គលិក (១.២) ការិយាល័យហិរញ្ញវត្ថុ និងផែនការ និង(១.៣)ការិយាល័យសុខុមាលភាពសង្គម និងជួញដូរមនុស្ស។

**១.១.ការិយាល័យរដ្ឋបាល និងបុគ្គលិក**

ការិយាល័យនេះមានភារកិច្ចដូចជា៖

**ផ្នែករដ្ឋបាល៖** មានតួនាទីក្នុងគ្រប់គ្រងឯកសាររបស់មន្ទីរទាំងឯកសារ ចេញចូល ការតម្កល់ឯកសារ ការតាក់តែងលិខិត រៀបចំលិខិតរដ្ឋបាលផ្សេងៗ និងការធ្វើកិច្ចសហការល្អជាមួយដៃគូដែលពាក់ព័ន្ធ។

**ផ្នែកបុគ្គលិក៖** មានតួនាទីគ្រប់គ្រងមន្ត្រីក្រោមឱវាទរបស់ខ្លួន ដូចជា ការវាយតម្លៃមន្ត្រីរាជការ ដំឡើងថ្នាក់ ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សជាដើម។[29]

**១.២.ការិយាល័យហិរញ្ញវត្ថុ និងផែនការ**

ការិយាល័យនេះមានភាកិច្ចដូចជា៖

**ផ្នែកហិរញ្ញវត្ថុ៖** មានតួនាទីគ្រប់គ្រងថវិកា ដែលមានដូចជា ការចំណាយទៅលើគ្រឿងបរិក្ខា ការចំណាយទៅលើផែនការសកម្មភាពនានា និងត្រូវធ្វើរបាយការណ៍ថវិកាជូនថ្នាក់ជាតិ។

[27] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតនៅក្រោមនាយកដ្ឋានសុខុមាលភាពសង្គម, លេខ ២២៤៩ ស.អ.យ., ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១, ប្រការ៣ កថាខណ្ឌ៣

[28] ប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លេខ ០៦៦ស.អ.យ., ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧, ប្រការ៣

[29] ប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លេខ ០៦៦ស.អ.យ., ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧, ប្រការ៤

**ផ្នែកផែនការ៖** មានតួនាទីកសាងផែនការអភិវឌ្ឍទៅតាមការណែនាំពីក្រសួង ចងក្រងទុកនូវបទដ្ឋាននានាក្នុងវិស័យសង្គមកិច្ច និងធ្វើរបាយការណ៍ជូនទៅក្រសួងគ្រប់សកម្មភាពនៃការិយាល័យផ្សេងបានធ្វើរៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ។[30]

### ១.៣. ការិយាល័យសុខុមាលភាពសង្គម និងជួញដូរមនុស្ស

នៅក្នុងការិយាល័យនេះត្រូវបានបែងចែកចេញជា ០៣ផ្នែកផ្សេងៗទៀតគឺ ផ្នែកសុខុមាលភាពសង្គម ផ្នែកសុខុមាលភាពជនពិការ និងផ្នែកប្រឆាំងការជួញដូរមនុស្ស។ ប៉ុន្តែនៅក្នុងការសិក្សានេះ នឹងលើកយកតែផ្នែកសុខុមាលភាពសង្គមមកសិក្សាប៉ុណ្ណោះ ដែលផ្នែកនេះមានតួនាទីដូចជា៖

- រៀបចំផែនការសកម្មភាព និងកម្មវិធីជួយសង្គ្រោះដល់ក្រុមងាយរងគ្រោះ និងជួបការលំបាកនៅមូលដ្ឋានដើម្បីទប់ស្កាត់ទុរគតភាព
- រៀបចំផែនការសកម្មភាព និងកម្មវិធីទាក់ទងជាមួយជនអនាថា និងការចំណាកស្រុកដែលគ្មានសុវត្ថិភាព
- ប្រារព្ធទិវាអន្តរជាតិ ស្តីពីគ្រួសារ១៥ឧសភា និងទិវាសិទ្ធិនារី ៨មីនារៀងរាល់ឆ្នាំ និងធ្វើផែនកាសកម្មភាពទាក់ទងនឹងគ្រួសារ និងយេនឌ័រ
- រៀបចំផែនការសកម្មភាព និងកម្មវិធីជួយជនដែលផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងមេរោគកាចសាហាវផ្សេងៗទៀត
- តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីជួយជនរងគ្រោះ និងងាយរងគ្រោះរបស់អង្គការដៃគូដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង
- អនុវត្តនូវភារកិច្ចផ្សេងៗដែលប្រធានមន្ទីរប្រគល់ជូន។

[30] ប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លេខ ០៦៦ស.អ.យ., ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧, ប្រការ៤

# ជំពូកទី៣

# សមិទ្ធិផលរបស់នាយកដ្ឋាន

# សុខុមាលភាពសង្គម

# ជំពូកទី៣
# សមិទ្ធផលទទួលបានរបស់នាយកដ្ឋានសុខុមាលភាពសង្គម

បើលើកឡើងអំពីសមិទ្ធផល នាយកដ្ឋានសុខុមាលភាពបានសម្រេចសមិទ្ធផលមកជាច្រើនស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ប៉ុន្តែនៅក្នុងការសិក្សាស្រាវជ្រាវនេះនឹងធ្វើការបង្ហាញមិត្តអ្នកអានតែសមិទ្ធផលធំៗមួយចំនួនដែលនាយកដ្ឋានបានសម្រេចក្នុងនីតិកាលទី៦នេះ ដែលមានដូចជា **(ផ្នែកទី១) ការធ្វើអង្កេតរហ័សនៃជនអនាថា (ផ្នែកទី២) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ** និង **(ផ្នែកទី៣) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩។**

## ផ្នែកទី១៖ ការធ្វើអង្កេតរហ័សនៃជនអនាថា

ការធ្វើអង្កេតរហ័ស នេះសម្តៅដល់កម្មវិធីដែលនាយកដ្ឋានបានបង្កើតឡើង ដើម្បីធ្វើការអង្កេតទៅលើជនអនាថា ដែលនៅក្នុងចំណុចនេះនឹងបង្ហាញមិត្តអ្នកអានចំនួន ០៣ដែលមានដូចជា (១) **សញ្ញាណនៃការអនុវត្តការធ្វើអង្កេតរហ័ស (២) គោលបំណង និង(៣) យន្តការនៃការអនុវត្ត។**

### ១. សញ្ញាណនៃការអនុវត្តការធ្វើអង្កេតរហ័ស

នៅក្នុងចំណុចសញ្ញាណទូទៅនេះ នឹងធ្វើការបង្ហាញទៅដល់មិត្តអ្នកអានអំពីសញ្ញាណនៃអ្នកអនុវត្ត និងជនដែលត្រូវបានអនុវត្តនៅក្នុងការអង្កេតរហ័សនេះ។

#### ១.១. អ្នកអនុវត្ត

នៅក្នុងការធ្វើអង្កេតរហ័សនេះត្រូវបានហៅថា ក្រុមការងារអង្កេតរហ័ស ដែលមានសមាសភាពដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (នាយកដ្ឋានសុខុមាលភាពសង្គម) ក្រសួងផែនការ ក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត អង្គការជាដៃគូ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសហភាពសហព័ន្ធយុវជនកម្ពុជា។[31] អ្នកអនុវត្តដែលត្រូវបានជ្រើសរើសជាអ្នកអង្កេតរហ័សត្រូវតែមានបុគ្គលិកលក្ខណៈល្អ មានភាពថ្លៃថ្នូរ និងមានក្រមសីលធម៌នានាដូចជា ការធ្វើការដោយយកក្រុមការងារជាធំ ត្រូវចេះគោរព និងយល់ចិត្តជនអនាថា មានទំនួលខុសត្រូវចំពោះការងាររបស់ខ្លួន ដែលសំខាន់ត្រូវមានទំនួលខុសត្រូវចំពោះរាជរដ្ឋាភិបាលចំពោះរាល់សមកម្មភាពរបស់ខ្លួនក្នុងការអនុវត្ត ត្រូវរក្សាការសម្ងាត់ ទាំងព័ត៌មានដែលជនរងគ្រោះបានផ្តល់មកក្រុមការងារ និងការសម្ងាត់ក្នុងក្រុមកិច្ចការ។[32] ក្រុមការងារនេះ គឺត្រូវឆ្លងកាត់ការបណ្តុះបណ្តាលពីនីតិវិធីក្នុងការទំនាក់ទំនងជាពិសេសគឺ ការពន្យល់អំពីនីតិវិធីនៃការអង្កេតរហ័សនេះតែម្តង។

[31] សៀវភៅស្តីពីវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអង្កេតរហ័សនៃជនអនាថា ឆ្នាំ២០២០

[32] សៀវភៅស្តីពីវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអង្កេតរហ័សនៃជនអនាថា ឆ្នាំ២០២០

### ១.២. ជនជាគោលដៅអនុវត្ត

ជនដែលជាត្រូវបានអនុវត្តនៅក្នុងការអង្កេតរហ័ស គឺជនអនាថា ដែលជនអនាថាជាជំពូកជនទីទំលក្រ ដែលគ្មានទីជម្រក តែលតោល គ្មានទីពឹង។[33] ជនអនាថាក៏ត្រូវបានបែងចែកចេញជា ០៣ប្រភេទគឺ៖

- **ជនរស់នៅអចិន្ត្រៃយ៍តាមទីសាធារណៈ៖** សំដៅទៅដល់ជនដែលបានកាត់ផ្តាច់ចំណងទាក់ទងជាមួយគ្រួសារ និងរស់នៅតែម្នាក់ឯង
- **ជនរស់នៅជាមួយគ្រួសារនៅតាមទីសាធារណៈ៖** សំដៅទៅដល់ជនរស់នៅជាមួយគ្រួសាររបស់ពួកគេតាមទីសាធារណៈ
- **ជនធ្វើការតាមទីសាធារណៈ៖** សំដៅដល់ជនដែលបានចំណាយពេលវេលាច្រើន របស់ពួកគេនៅទីសាធារណៈ ដើម្បីទទួលបានប្រាក់ចំណូលសម្រាប់គ្រួសារពួកគេ ប៉ុន្តែពួកគេត្រលប់ទៅទីស្នាក់នៅរបស់ពួកគេវិញ។ ក្រុមជនទាំងនេះ ប្រកបមុខរបរដែលធ្វើឱ្យប៉ះពាល់ដល់របៀបរបបសណ្តាប់ធ្នាប់សង្គម។[34]

## ២. គោលបំណង

នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតកម្មវិធីអង្កេតរហ័សនៃជនអនាថានេះឡើង ក្នុងគោលបំណងប្រមូលទិន្នន័យអំពីជនអនាថានៅប្រទេសកម្ពុជា ដើម្បីបញ្ចូលលទ្ធផលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិរយៈពេល៥ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំនៃគណៈកម្មាធិការជនអនាថា ដើម្បីប្រើប្រាស់គំហើញនានា នៅក្នុងការឆ្លើយតប និងផ្តល់សេវាកាន់តែល្អប្រសើរដល់ជនអនាថា និងដើម្បីផ្តល់ជាភស្តុតាងសម្រាប់ការរៀបចំផែនការថវិកាដើម្បីឱ្យអភិបាលកិច្ចនៅគ្រប់កម្រិតទទួលបានធនធានកាន់តែល្អប្រសើរក្នុងការពង្រឹងការឆ្លើយតបរបស់ខ្លួនចំពោះជនអនាថា។

## ៣. យន្តការនៃការអនុវត្ត

នៅក្នុងយន្តការនៃការអនុវត្តអង្កេតរហ័ស គឺត្រូវធ្វើការអត់ធ្មត់ ទើបបានជាក្រុមការងារអង្កេតរហ័សត្រូវតែជាជនដែលមានបុគ្គលិកលក្ខណៈល្អដែលឆ្លងកាត់ការបណ្តុះបណ្តាលជាច្រើនវគ្គ។ ការអនុវត្តការអង្កេតរហ័សនេះ គឺតម្រូវឱ្យក្រុមអង្កេតរហ័ស មានទំនាក់ទំនងជាមួយនឹងជនអនាថា រួចធ្វើការសម្ភាសន៍ជនអនាថាទៅតាមទម្រង់កិច្ចសម្ភាសន៍ដែលមានស្រាប់[35]។ ក្រោយពីបញ្ចប់កិច្ចសម្ភាសន៍ ក្រុមការងារអង្កេតរហ័សត្រូវធ្វើការបញ្ជូនទិន្នន័យតាមរយៈប្រព័ន្ធអេឡិចត្រូនិច(ទូរស័ព្ទ) មកកាន់ក្រុមការងារត្រួតពិនិត្យ និងតាមដានធ្វើការបញ្ចូលក្នុងទិន្នន័យរួចបញ្ជូនទៅកាន់ស្ថាប័នដែលពាក់ព័ន្ធ។

---

[33] អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា, លេខ១២៥អនក្រ.បក ,ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥,មាត្រា២

[34] សៀវភៅស្តីពីគោលការណ៍ណែនាំសម្រាប់ជួយជនអនាថា, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១

[35] ទម្រង់កិច្ចសម្ភាសន៍នឹងត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសុខុមាលភាពសង្គម

ការអនុវត្តការអង្កេតរហ័សជនអានាថារយៈពេល០១ឆ្នាំកន្លងមក(ឆ្នាំ២០២០) នាយកដ្ឋានបានលទ្ធផលជាទីគាប់ចិត្ត គឺការទទួលបានទិន្នន័យពីជនអនាថាយ៉ាងរហ័សដែលទិន្នន័យរួមមាន ជនអនាថាជាកុមារមានចំនួន ៦៥៥នាក់(ស្រី ២៦៥នាក់) ជនអនាថាជាយុវវ័យមានចំនួន ១៨៧នាក់(ស្រី ៩៦នាក់) ជនអនាថាជាមនុស្សពេញវ័យមានចំនួន ១៩៥៥នាក់(ស្រី៦៩៨ នាក់) និងជនពិការជាមនុស្សចាស់មានចំនួន ៣៧៥នាក់(ស្រី២៤៧នាក់)។[36] ការទទួលបានទិន្នន័យរហ័ស ការឆ្លើយតបក្នុងការផ្តល់ជាជំនួយទៅកាន់ជនរងគ្រោះក៏រហ័ស និងមានភាពច្បាស់លាស់ ជាពិសេសការទទួលបានទិន្នន័យច្បាស់លាស់ជាហេតុធ្វើការដាក់ផែនការថវិកាក៏ច្បាស់លាស់ក្នុងការចំណាយស្របទៅតាមលទ្ធកម្មសាធារណៈ។

## ផ្នែកទី២៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

កម្មវិធីនេះ ជាកម្មវិធីនេះនាយកដ្ឋានបានអនុវត្ត និងកំពុងបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន ហើយកម្មវិធីនេះជាកម្មវិធីមួយដ៏សំខាន់ព្រោះវាបានរួមចំណែកកាត់បន្ថយហានិភ័យនៃការស្លាប់កុមារ ការស្លាប់ទារកក្នុងផ្ទៃ និងជាពិសេសការស្លាប់ទាំងម្តាយទាំងកូន។ ក្នុងចំណុចនេះ អ្នកនិស្សិតនឹងបានដឹងអំពី **(១)គោលបំណង (២) ការពិនិត្យតាមដានការអនុវត្ត (៣)ដំណើរការនៃការអនុវត្ត** និង**(៤)យន្តការនៃការអនុវត្តកម្មវិធី**។

### ១. គោលបំណង

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ត្រូវបានអនុវត្តក្រោមអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដែលស្តីពីការអនុវត្តកម្មវិធីនេះ។ ការបង្កើតកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ មានគោលបំណងលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហាររូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងពីកូនក្នុងផ្ទៃ រហូតដល់កូនមានអាយុ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។ មាតា និងទារកនឹងទទួលបានការត្រួតពិនិត្យសុខភាពទៅតាមដំណាក់កាលដែលដំណាក់កាលនេះ និស្សិតនឹងសិក្សាយល់ច្បាស់នៅចំណុចខាងក្រោម។ ចំពោះទារកដែលមានអាយុក្រោម២ឆ្នាំវិញ កុមារនឹងទទួលបានការចាក់វ៉ាក់សាំងរហូតដល់មានអាយុ២ឆ្នាំការនេះ ធ្វើឱ្យកុមារធំលូតលាស់ដោយមានសុខភាពល្អ។

### ២. ការពិនិត្យតាមដានការអនុវត្ត

នៅក្នុងចំណុចនេះនឹងធ្វើការបង្ហាញដល់និស្សិតអំពីនីតិវិធីក្នុងការចូលរួមក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់តាំងពីដំណាក់កាល**(២.១)ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង** និង**(២.២)ការអនុវត្តលក្ខខណ្ឌ**។

[36] សៀវភៅស្តីពីគោលការណ៍ណែនាំសម្រាប់ជួយជនអនាថា, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១

### ២.១. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង

**ការចុះឈ្មោះ** គឺជាការផ្តល់លទ្ធភាពឲ្យស្ត្រីដែលមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលបំពេញតាមលក្ខខណ្ឌ អាចចុះឈ្មោះចូលក្នុងកម្មវិធីដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ ហើយការចុះឈ្មោះត្រូវបានធ្វើឡើងជាប្រចាំតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ ស្ត្រីដែលមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំត្រូវចុះឈ្មោះក្នុងកម្មវិធី នៅសាលាឃុំ សង្កាត់ណាមួយ ហើយដើម្បីចុះឈ្មោះបាន ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំត្រូវបំពេញលក្ខខណ្ឌ និងភ្ជាប់មកជាមួយឯកសារដូចជា ៖

- **ករណីស្ត្រីមានផ្ទៃពោះ៖** បានពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច១ដង ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតា និងត្រូវមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព
- **ករណីកុមារអាយុក្រោម២ឆ្នាំ៖** ត្រូវមានប័ណ្ណសុខភាពកុមារ (សម្រាប់កុមារដែលម្តាយបានចុះឈ្មោះចូលក្នុងកម្មវិធីរួច កុមារនោះត្រូវបានចុះឈ្មោះជាស្វ័យប្រវត្តិ) ត្រូវមានប័ណ្ណសុខភាពកុមារ និងប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាពរបស់គ្រួសារកុមារ (សម្រាប់កុមារដែលម្តាយមិនបានចុះឈ្មោះក្នុងកម្មវិធី)។

**ការបើកផ្តល់លើកដំបូង៖** ក្រោយពីបានទទួលនូវឯកសារគ្រប់គ្រាន់ពីសំណាក់ស្ត្រី និងកុមារអ្នកអនុវត្តត្រូវធ្វើការចុះឈ្មោះ និងបើកផ្តល់លើកដំបូង៖

- បញ្ចូលព័ត៌មានអ្នកទទួលផល ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ចូលព័ត៌មានអំពីប័ណ្ណគណនីធនាគារទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ថតរូបអ្នកទទួលផល និងថតឯកសារសម្រាប់ការចុះឈ្មោះ និងប័ណ្ណគណនីធនាគារចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងសំណៅឯកសារនៃការចុះឈ្មោះរបស់អ្នកទទួលផលឱ្យបានត្រឹមត្រូវ ដើម្បីអនុម័តការបើកផ្តល់លើកដំបូង។ ក្នុងករណីដែលទិន្នន័យមិនទាន់គ្រប់គ្រាន់ ឬខុសឆ្គង មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ឱ្យកែតម្រូវឡើងវិញ
- ផ្តល់ប័ណ្ណគណនីធនាគារដល់អ្នកទទួលផល និងណែនាំការប្រើប្រាស់ប័ណ្ណគណនីធនាគារ ការថែរក្សាលេខសម្ងាត់ ការបើកផ្តល់ និងទីតាំងបើកផ្តល់
- ស្ថាប័នបើកផ្តល់ ត្រូវផ្ទេរសាច់ប្រាក់ភ្លាមៗ ទៅក្នុងគណនីធនាគាររបស់អ្នកទទួលផល
- អ្នកទទួលផលអាចទៅដកប្រាក់ពីភ្នាក់ងារបើកផ្តល់នៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស
- បានពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច១ដង ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតា និងត្រូវមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព

- ត្រូវមានប័ណ្ណសុខភាពកុមារ (សម្រាប់កុមារដែលម្តាយបានចុះឈ្មោះចូលក្នុងកម្មវិធីរួចហើយ)។[37]

**២.២. ការអនុវត្តលក្ខខណ្ឌ**

ក្រោយពីទទួលបានការចុះឈ្មោះចូលក្នុងកម្មវិធី និងទទួលបានការឧបត្ថម្ភសាច់ប្រាក់លើកដំបូងរួច អ្នកទទួលផលត្រូវបន្តអនុវត្តន៍លក្ខខណ្ឌរបស់គម្រោង ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់។ ករណីខកខាន ការដកសាច់ប្រាក់តាមកាលបរិច្ឆេទកំណត់ អ្នកទទួលផលត្រូវរាយការណ៍ជូនមន្ត្រីឃុំ ភូមិ ឃុំ សង្កាត់ មូលដ្ឋានសុខាភិបាលសាធារណៈ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបានព័ត៌មាននៃការអនុវត្តដំណើរការនៃការបើកផ្តល់ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានដោយស្វ័យប្រវត្តិ និងដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់តាមដំណាក់កាលនីមួយៗដូចដែលបានរៀបរាប់ខាងក្រោម៖

- **តំណាក់កាលទី១** ៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០០០០រៀល ក្នុង១ដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន៤ដង មុនពេលសម្រាលកូន
- **តំណាក់កាលទី២** ៖ ផ្តល់ការឧបត្ថម្ភចំនួន ២០០០០០រៀល តែ១ដងគត់ នៅពេលសម្រាលកូន
- **តំណាក់កាលទី៣** ៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០០០០រៀល ក្នុង១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង ក្នុងនោះ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាព ក្រោយពេលសម្រាលកូន និង៧ដង នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ២ឆ្នាំ ។[38]

**៣. យន្តការនៃការអនុវត្តកម្មវិធី**

ក្នុងការអនុវត្តកម្មវិធីនេះ គឺត្រូវបានបែងចែកចេញជាពីរថ្នាក់ទៅតាមប្រព័ន្ធរដ្ឋបាលនៃការដឹកនាំប្រទេសរបស់រាជរដ្ឋាភិបាលគឺ (៣.១) ក្រសួងស្ថាប័ន និង(៣.២) អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣.១. ក្រសួង ស្ថាប័នថ្នាក់ជាតិ**

នៅក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ មានការចូលរួមពីសំណាក់ស្ថាប័នពាក់ព័ន្ធជាច្រើនដែលស្ថាប័ននីមួយៗមានតួនាទីផ្សេងៗគ្នាស្របទៅតាមតួនាទីចម្បងរបស់ខ្លួន៖

**ក្រុមប្រឹក្សាជាតិគាំពារសង្គម** មានតួនាទី និងភារកិច្ច ដូចជា សម្របសម្រួលកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធី ពិនិត្យតាមដាន និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី។

[37] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

[38] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាស្ថាប័នទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងការអនុវត្តគម្រោង ដែលមាននាយកដ្ឋានសុខុមាលភាពសង្គមជាសេនាធិការ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំគណៈកម្មការបច្ចេកទេស ដើម្បីអនុវត្តន៍គម្រោង។ គណៈកម្មការបច្ចេកទេសមានក្រុមការងារប្រតិបត្តិកម្មវិធី ក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ។

**ក្រសួងមហាផ្ទៃ** គឺជាស្ថាប័នគាំទ្រ និងសម្របសម្រួលការអនុវត្តកម្មវិធី ហើយក្រសួងមហាផ្ទៃសម្របសម្រួលជាមួយថ្នាក់ក្រោមជាតិ ដើម្បីរៀបចំយន្តការក្នុងការគាំទ្រអនុវត្តន៍កម្មវិធី លើសពីនេះក្រសួងមហាផ្ទៃមានតួនាទី និងភារកិច្ចដូចជា រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តតួនាទីរបស់អង្គភាពពាក់ព័ន្ធរបស់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងយន្តការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យតាមដាន និងគាំទ្រការអនុវត្តកម្មវិធី សហការក្នុងការពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហានានានៃការអនុវត្តកម្មវិធី។

**ក្រសួងសុខាភិបាល** បានដើរតួនាទីក្នុងការអនុវត្តកម្មវិធី ដូចជា រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តកម្មវិធីតាមការចាំបាច់ សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលពាក់ព័ន្ធការអនុវត្តកម្មវិធីដល់មូលដ្ឋានសុខាភិបាលសាធារណៈ សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជំរុញមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីពង្រឹងការបញ្ជាក់នៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី ។

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** សម្របសម្រួលការផ្ទេរថវិកាសម្រាប់គាំទ្រការអនុវត្តកម្មវិធី ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចជា ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់អនុវត្តន៍កម្មវិធី វិភាជន៍ថវិកាសម្រាប់ការបើកផ្តល់របបឧបត្ថម្ភជូនទៅអ្នកទទួលផល ពិនិត្យរបាយការណ៍សកម្មភាពការងារ ហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី។

**ក្រសួងផែនការ** គាំទ្រ និងផ្តល់នូវទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រ ហើយក្រសួងផែនការ មានតួនាទី និងភារកិច្ចដូចជា ផ្តល់ទិន្នន័យគ្រួសារក្រីក្រដែលមានសុពលភាពសម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបញ្ចូលទិន្នន័យគ្រួសារក្រីក្រជាមួយនឹងកម្មវិធីប្រព័ន្ធគ្រប់គ្រងព័ត៌មាន សម្របសម្រួល និងលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រការអនុវត្តកម្មវិធី ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី។

**ក្រុមការងារបច្ចេកទេសអន្តរក្រសួង** មានតួនាទីក្នុងការសម្របសម្រួលការអនុវត្តកម្មវិធី សម្របសម្រួលក្នុងការអភិវឌ្ឍសមត្ថភាព និងការផ្សព្វផ្សាយដោយមានកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័នពាក់ព័ន្ធ គាំទ្រការផ្តល់ និងការធ្វើសមាហរណកម្មទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្ររបស់ក្រសួងផែនការ គាំទ្រការផ្ទេរទិន្នន័យការធ្វើសមាហរណកម្មទិន្នន័យ និងការបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលពីក្រសួងសុខាភិបាល ត្រួតពិនិត្យ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម។[39]

**៣.២. អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលរាជធានី ខេត្តមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មន្ទីរពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- សម្របសម្រួល និងចូលរួមផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ដឹកនាំកិច្ចប្រជុំនៅថ្នាក់រាជធានី ខេត្ត ដើម្បីដោះស្រាយបញ្ហាក្នុងការអនុវត្តកម្មវិធី
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ដែលរៀបចំដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។
- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធីប្រចាំថ្ងៃ
- រៀបចំផែនការសកម្មភាព និងថវិកា សម្រាប់ការអនុវត្តកម្មវិធីដូចជា កសាងសមត្ថភាព ការផ្សព្វផ្សាយការពិនិត្យតាមដាន និងការដោះស្រាយបណ្តឹងតវ៉ា
- កសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់ឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី

[39] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

- ពិនិត្យតាមដានដំណើរការចុះឈ្មោះ និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផល តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត មន្ទីរសុខាភិបាល និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី
- សហការជាមួយស្ថាប័នបើកផ្តល់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការបើកផ្តល់
- ដឹកនាំកិច្ចប្រជុំប្រចាំសប្តាហ៍របស់ក្រុមការងារនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី
- ចុះពិនិត្យតាមដានការអនុវត្តកម្មវិធីនៅឃុំ សង្កាត់ និងសហគមន៍
- គាំទ្រ និងដោះស្រាយបណ្តឹងតវ៉ា និងការក្លែងបន្លំរបស់អ្នកទទួលផល ដែលស្នើឡើងដោយឃុំ សង្កាត់
- បញ្ជូនករណីអំពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅមន្ទីរសាមីឬគណៈកម្មការបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធ្វើការដោះស្រាយ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ និងផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរដែលពាក់ព័ន្ធនៅក្នុងការផ្តល់ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
- គាំទ្រឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការអប់រំផ្សព្វផ្សាយ
- ពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយ
- ដោះស្រាយបញ្ហាជាប្រចាំអំពីការប្រើប្រាស់ ឬការរអាក់រអួលរបស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ពិនិត្យគុណភាពទិន្នន័យដែលបានបញ្ចូល និងផ្តល់ព័ត៌មានត្រឡប់ដល់ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ
- បូកសរុបរបាយការណ៍អំពីសកម្មភាពវគ្គបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយ។[40]

[40] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

### ៣.៣. ស្ថាប័នបើកផ្តល់

ស្ថាប័នបើកផ្តល់ មានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- សហការក្នុងការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី
- ផ្តល់ប័ណ្ណគណនីធនាគារដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បើកគណនីធនាគារដល់អ្នកទទួលផល
- ណែនាំ និងផ្តល់ខិតប័ណ្ណអំពីការប្រើប្រាស់ប័ណ្ណគណនីធនាគារ និងទីតាំងបើកផ្តល់
- ដាក់ឱ្យប្រើប្រាស់ទូរស័ព្ទទាន់ហេតុការណ៍សម្រាប់កម្មវិធី ដើម្បីដោះស្រាយបញ្ហា
- ណែនាំភ្នាក់ងារបើកផ្តល់អំពីនីតិវិធីបើកប្រាក់ដល់អ្នកទទួលផលនៃកម្មវិធី
- សហការក្នុងការដោះស្រាយបញ្ហាប្រឈមនានា
- ផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីធនាគាររបស់អ្នកទទួលផលភ្លាមៗបន្ទាប់ពីទទួលបានការអនុម័ត
- ជូនដំណឹងដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាបន្ទាន់ករណីមានការពន្យារពេល
- ផ្តល់របាយការណ៍អំពីការផ្ទេរសាច់ប្រាក់ដែលជោគជ័យ និងមិនជោគជ័យ។ ករណីការផ្ទេរសាច់ប្រាក់មិនបានជោគជ័យត្រូវបញ្ជាក់ពីមូលហេតុ
- ផ្តល់របាយការណ៍នៃការដកប្រាក់ចេញពីគណនីធនាគាររបស់អ្នកទទួលផល
- គាំទ្រដល់ដំណើរការផ្ទៀងផ្ទាត់ ការទូទាត់ ដោយផ្តល់ទិន្នន័យដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[41]

### ៣.៤.ដំណើរការនៃការបើកផ្តល់

ជាដំបូងក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា បញ្ជូនព័ត៌មានអំពីការអនុវត្តលក្ខខណ្ឌតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានទៅស្ថាប័នបើកផ្តល់ រួចស្ថាប័នបើកផ្តល់ផ្ទេរសាច់ប្រាក់ភ្លាមៗទៅក្នុងគណនីធនាគាររបស់អ្នកទទួលផល។ ក្នុងករណីថាមានបញ្ហាបច្ចេកទេសណាមួយស្ថាប័នបើកផ្តល់មិនត្រូវធ្វើការផ្ទេរសាច់ប្រាក់នោះឡើង គឺត្រូវបញ្ជូនព័ត៌មានទៅកាន់ក្រុមការងារប្រតិបត្តិវិញ ហើយត្រូវតែតាមដានកាលវិភាគបើកផ្តល់សាច់ប្រាក់ដែលបានចេញដោយគម្រោង និងជាចុងបញ្ចប់អ្នកទទួលផលត្រូវទៅដកសាច់ប្រាក់ និងដកប្រាក់ពីភ្នាក់ងារបើកផ្តល់នៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស។[42]

---

[41] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

[42] សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

## ផ្នែកទី៣៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩នេះ ត្រូវបានបង្កើតឡើងស្របទៅតាមស្ថានភាពសង្គមជួបប្រទះនូវជំងឺរាតត្បាតដែលធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច ស្ថានភាពសុខភាពត្រូវបានប្រែប្រួល។ ស្របទៅតាមការអនុវត្តនូវគោលការណ៍៣កុំ ៣ការពាររបស់រាជរដ្ឋាភិបាល ប្រជាជនត្រូវបានកាត់បន្ថយចេញក្រៅ បានធ្វើឱ្យមានភាពប៉ះពាល់យ៉ាងខ្លាំងទៅដល់សេដ្ឋកិច្ចរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនេះ នាយកដ្ឋានសុខុមាលភាពសង្គមបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះឡើង ដែលនីតិវិធីក្នុងការអនុវត្តគឺមានលក្ខណៈស្របទៅតាមកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ[43]។ នៅក្នុងកិច្ចការនេះនឹងបង្ហាញមិត្តអ្នកអាន**នូវ (១)ដំណើរការនៃកម្មវិធី (២)ការត្រួតពិនិត្យលើការអនុវត្ត (៣)ការដោះស្រាយបណ្តឹងឧបាស្រ័យ** និង**(៤)យន្តការគាំទ្រការអនុវត្តកម្មវិធី**។

### ១. ដំណើរការនៃកម្មវិធី

ការផ្ទៀងផ្ទាត់ឈ្មោះឱ្យគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌កម្រិតភាពក្រីក្រ១ ឬកម្រិតភាពក្រីក្រ២ដែលមានសុពលភាព អាចផ្ទៀងផ្ទាត់បាន តាមប្រព័ន្ធបច្ចេកវិទ្យានៅតាមឃុំ សង្កាត់ ដែលនៅជិតទីស្នាក់នៅរបស់ជនរងគ្រោះ។ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភនៅក្នុងកម្មវិធីនេះ គឺត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនដូចជា៖ មានប័ណ្ណសមធម៌កម្រិត១ ឬកម្រិត២ដែលមានសុពលភាព ត្រូវទៅផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធីនៅតាមឃុំ សង្កាត់ណាដែលនៅជិតលំនៅឋាន។[44] គ្រួសារក្រីក្រ និងងាយរងគ្រោះដែលបានផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធី ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ផ្អែកតាមទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយគិតចាប់ពីថ្ងៃបានផ្ទៀងផ្ទាត់ឈ្មោះនៅឃុំ សង្កាត់រហូតដល់បិទកម្មវិធី។ មិនតែប៉ុណ្ណោះមេឃុំ ឬចៅសង្កាត់ត្រូវទទួលខុសត្រូវក្នុងការផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធី ដោយចាត់តាំងអ្នកទទួលបន្ទុកកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៅឃុំ សង្កាត់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឈ្មោះតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ហើយអ្នកទទួលផលត្រូវទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយដោយយកនូវប័ណ្ណសមធម៌ ភ្នាក់ងារវីងបានផ្ទៀងផ្ទាត់លេខគណនីធនាគារដោយប្រើប្រាស់លេខប័ណ្ណសមធម៌ និងថតរូបអ្នកបើកប្រាក់ដោយមានការកាន់ប័ណ្ណសមធម៌ រួចក៏ដាក់ចូលទៅប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

[43] អនុក្រឹត្យស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសាក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, លេខ ៨៨ អនក្រ.បក, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០, មាត្រា៦

[44] អនុក្រឹត្យស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសាក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, លេខ ៨៨ អនក្រ.បក, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤

## ២. ការត្រួតពិនិត្យលើការអនុវត្តកម្មវិធី

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវតាមដាន និងពិនិត្យទៅលើវឌ្ឍនភាព និងការអនុវត្តកម្មវិធីជាប្រចាំថ្ងៃ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន រៀបចំកិច្ចប្រជុំជាមួយមន្ទីរស.អ.យ ឬរដ្ឋបាលឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ តាមដានលើទិន្នន័យតាមប្រព័ន្ធអនឡាញ រៀបចំរបាយការណ៍វឌ្ឍនភាព និងការបញ្ចប់ការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ។ មន្ទីរស.អ.យ. ត្រូវត្រួតពិនិត្យលើវឌ្ឍនភាព និងការអនុវត្តកម្មវិធីជាប្រចាំថ្ងៃ រៀបចំកិច្ចប្រជុំឃុំ សង្កាត់ ចុះតាមដានការអនុវត្តតាមឃុំ និងសង្កាត់ ចូលរួមក្នុងដំណើរការអនុវត្តកម្មវិធី និងធ្វើអង្កេតរហ័ស និងរាយការណ៍អំពីវឌ្ឍភាព និងបញ្ហាប្រឈមទៅរដ្ឋបាលរាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ឃុំ សង្កាត់ ត្រូវតាមដានការត្រួតពិនិត្យការចូលរួមការអនុវត្តកម្មវិធីរបស់អ្នកទទួលផល ត្រួតពិនិត្យឈ្មោះ ដើម្បីធានាថាព័ត៌មានដែលយើងទទួលបានទាំងនោះគឺត្រឹមត្រូវ និងរាយការណ៍បញ្ហាប្រឈម និងបណ្តឹងតវ៉ាដែលមិនអាចដោះស្រាយបានមកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ៣. យន្តការដោះស្រាយបណ្តឹងឧបាស្រ័យ

យន្តការនេះគឺយើងបានសំដៅទៅដល់ការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល បន្ទាប់ពីបានផ្ទៀងផ្ទាត់ឈ្មោះរួចពាក់ព័ន្ធនឹងការបាត់ ឬខូចប័ណ្ណសមធម៌ មិនអាចបើកប្រាក់ឧបត្ថម្ភបាន ប្រាប់ឧបត្ថម្ភមិនបានបញ្ចូលក្នុងគណនី ភ្លេចពាក្យសម្ងាត់ និបញ្ហាផ្សេងៗទៀត ។ អ្នកទទួលផលដែលមានបំណងចង់ប្តឹងតវ៉ាអាចដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬជាពាក្យសំដីដោយផ្ទាល់ទៅរដ្ឋបាលឃុំ សង្កាត់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយការដោះស្រាយនូវបណ្តឹងតវ៉ារបស់អ្នកទទួលផលនោះមានដូចជា បន្ទាប់ពីឃុំ សង្កាត់ ទទួលបានបណ្តឹងតវ៉ានោះហើយ គឺត្រូវដោះស្រាយ មិនឱ្យលើសពីរយៈពេល ១ថ្ងៃនោះទេ តែប្រសិនបើឃុំ សង្កាត់ ដោះស្រាយមិនបានទេ គឺត្រូវតែបញ្ជូនបណ្តឹងតវ៉ានោះទៅឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដោះស្រាយបន្តហើយក្នុងករណីមន្ទីដោះស្រាយមិនបានទៀត មន្ត្រីប្រតិបត្តិកម្មវិធីត្រូវបញ្ជូនពាក្យបណ្តឹងតវ៉ាទាំងនោះ ទៅកាន់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្ទាប់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលហើយគឺក្រសួងត្រូវពិនិត្យ ស៊ើបអង្កេត និងធ្វើការដោះស្រាយ លទ្ធផលចេញពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាលទ្ធផលស្ថាពរ។

## ៤. យន្តការការគាំទ្រនៃការអនុវត្តកម្មវិធី

យន្តការគាំទ្រនៃការអនុវត្តកម្មវិធីនេះត្រូវប្រើប្រាស់យន្តការដែលមានស្រាប់ ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដោយមានការបន្ថែមនូវការទទួលខុសត្រូវមួយចំនួនដូចខាងក្រោម ៖

**ថ្នាក់ជាតិ**

- សម្របសម្រួលកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដាន និងផ្តល់យោបល់លើការអនុវត្តកម្មវិធី
- ដឹកនាំ គ្រប់គ្រងកម្មវិធី
- រៀបចំផែនការសកម្មភាព គម្រោងថវិកា ឯកសារគតិយុត្ត និងយន្តការក្នុងកម្មវិធី
- ផ្សព្វផ្សាយការយល់ដឹងអំពីការអនុវត្តកម្មវិធីដល់សាធារណៈជន
- គាំទ្រ និងផ្តល់បច្ចេកទេសដល់ឃុំ សង្កាត់ និងមន្ទីរ
- សហការជាមួយស្ថាប័នធនាគារ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកម្មវិធី
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃកម្មវិធី
- ពិនិត្យរបាយការណ៍សកម្មភាពការងារ
- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ
- ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន និងវាយតម្លៃ
- ចេញប័ណ្ណសមធម៌ទុតិយតាដល់អ្នកទទួលផល។

**ថ្នាក់ក្រោមជាតិ**

- គាំទ្រ និងចូលរួមផ្សព្វផ្សាយការយក់ដឹងអំពីកម្មវិធីដល់សាធារណៈជន
- បង្កើនសមត្ថភាពបន្ថែមដល់មន្ត្រីកាន់កម្មវិធី
- តាមដានត្រួតពិនិត្យការងាររបស់មន្ត្រី
- គាំទ្របច្ចេកទេសដល់ឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកម្មវិធី
- សហការ និងគាំទ្រដល់ឃុំ សង្កាត់ក្នុងការអនុវត្តកម្មវិធី
- ជំរុញ និងពង្រឹងរដ្ឋបាលឃុំ សង្កាត់
- ដឹកនាំ និងគ្រប់គ្រងដំណើរការអនុវត្តកម្មវិធី
- បញ្ជាក់ និងវាយតម្លៃលើប័ណ្ណសមធម៌
- រាយការណ៍វឌ្ឍនភាពនៃកម្មវិធីជូនរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរស.អ.យ.។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នាយកដ្ឋានសុខុមាលភាពសង្គម គឺជានាយកដ្ឋានមួយដែលបានរួមចំណែកក្នុងការជួយសង្គម ក៏ដូចជាជួយដល់ជនក្រីក្រឱ្យទទួលបានការឧបត្ថម្ភ និងទទួលបាននូវសេវាសង្គមកិច្ចដែលជាសេវាដែលជនគ្រប់រូបត្រូវទទួលបាន។ បើពិនិត្យមើលទៅលើរចនាសម្ព័ន្ធរបស់នាយកដ្ឋាននេះ ការិយាល័យនីមួយៗ គឺសុទ្ធសឹងតែមានតួនាទីស្របទៅតាមតួនាទីរបស់កិច្ចគាំពាំរសង្គម គឺប្រព័ន្ធគាំពាំរសង្គម។ នាយកដ្ឋានសុខុមាលភាពសង្គមបានធ្វើការជាមួយជនរងគ្រោះ ដែលមានភាពលំបាកក្នុងសង្គម រួមមាន កិច្ចគាំពារស្ត្រី ជនអនាថា ជអនាថាវិបល្លាសស្មារតី ជនរងគ្រោះដោយសារជំងឺអេដស៍ ជនដែលផ្ទុកមេរោគអេដស៍ ជនដែលរងគ្រោះដោយសារគ្រោះមហន្តរាយនានា។ ចំពោះកិច្ចគាំពារស្ត្រី នាយកដ្ឋាននេះបានអនុវត្តកម្មវិធីបញ្ជ្រាបយេនឌ័រ ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងគ្រួសារ ការរួមប្រឆាំងនឹងអំពើហិង្សាលើស្ត្រីក្នុងគ្រួសារ និងការបង្ហាត់បង្ហាញទៅដល់គ្រួសារក្នុងការអនុវត្តនូវកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន ដែលជាផ្នែកមួយនៃការអភិវឌ្ឍន៍ធនធានក្នុងប្រទេសកម្ពុជា។ ចំពោះការសង្គ្រោះជនផ្ទុកមេរោគអេដស៍ និងជនដែលរងគ្រោះដោយសារជំងឺអេដស៍ នាយកដ្ឋានបានធ្វើការបង្កើតនូវបទដ្ឋាននានាក្នុងការផ្តល់ជាជំនួយ ផ្តល់ការលើកទឹកចិត្តដែលមានប្រសិទ្ធិភាព ជាពិសេសការលុបបំបាត់ការរើសអើងជនដែលផ្ទុកមេរោអអេដស៍នៅក្នុងសង្គម។ ជនរងគ្រោះដែលទទួលបានការខូចខាតដោយសារតែគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយនានា ឬជាជនទីទ័លក្រក្នុងសង្គម គឺត្រូវបាននាយកដ្ឋានផ្តល់ជាជំនួយទៅដល់ជននោះដែលជំនួយទាំងនោះអាចជាថវិការដ្ឋ ឬជាថវិកាដែលទទួលបានការឧបត្ថម្ភពីសំណាក់អង្គការដៃគូ។ ជំនួយដែលនាយកដ្ឋានផ្តល់ជូន រួមមាន ថវិកា ស្បៀងអាហារ សម្ភារប្រើប្រាស់ មុង កន្ទេល ទឹកត្រី អង្ករ មី។ល។ ងាកមកមើលជនអនាថាវិញ ជននេះក៏ត្រូវបាននាយកដ្ឋានសុខុមាលភាពសង្គមយកចិត្តទុកដាក់ក្នុងការគាំពារយ៉ាងស្វិតស្វាញបំផុត។ នាយកដ្ឋានត្រូវធ្វើការបង្កើតនូវកម្មវិធីនានាដើម្បីធ្វើយ៉ាងណាផ្តល់ជំនួយទៅដល់ជនទាំងនេះបានទាន់ពេលវេលា និងការធ្វើជារបាយការណ៍ទៅកាន់ក្រសួងសេដ្ឋកិច្ចនូវចំនួនដែលត្រូវចំណាយស្របទៅតាមជនរងគ្រោះ។ ការផ្តល់ជំនួយនេះ នាយកដ្ឋានបានផ្តល់ជាទីកន្លែងស្នាក់ ផ្តល់ជាចំណីអាហារហូបចុក និងការបង្រៀននូវជំនាញនានា និងព្យាយាមសមាហរណកម្មជនអនាថាដែលអាចរស់នៅក្នុងសង្គមវិញបាន។ ការផ្តល់ជាជំនួយនេះ មិនមែនតែជាការផ្តល់ជំនួយតែជនអនាថាដែលមានសតិគ្រប់គ្រាន់នោះទេ ជនអនាថាដែលវិបល្លាស្មារតីក៏ត្រូវបានាយកដ្ឋានចាត់ជាគោលដៅក្នុងការអនុវត្តផងដែរ តួយ៉ាងនៅក្នុងឆ្នាំ២០១៩ នាយកដ្ឋានបានបង្កើតនូវមជ្ឈមណ្ឌលថែរទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ដើម្បីទទួលយកជនដែលមានបញ្ញាស្មារតីមិនគ្រប់គ្រាន់មកធ្វើការថែរទាំ ប៉ុន្តែចំពោះដំណើរការនៃការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ មិនទាន់បានចេញជាផ្លូវការឡើយ គឺស្ថិតនៅជាសេចក្តីព្រៀងនៅឡើយ។

ជារួមមកយើងសង្កេតឃើញថា នាយកដ្ឋានសុខុមាលភាពសង្គមមានតួនាទីក្តោបរួមទៅលើសុខុមាលភាពរបស់សង្គមទាំងមូលដែលមានរួមមានការកំណត់ជនដែលជាគោលដៅសុទ្ធសឹងតែជាជនដែលងាយរងគ្រោះដែលមានដូចជា ស្ត្រី កុមារ គ្រួសារក្រីក្រ ជនអនាថា និងជនរងគ្រោះដោយសារផ្ទុកមេរោគអេដស៍។ ជនទាំងនេះនឹងត្រូវបានការយកចិត្តទុកដាក់ពីសំណាក់នាយកដ្ឋានសុខុមាលភាពសង្គមស្របទៅតាមផែនការនានាដែលនាយកដ្ឋានសម្រេច គឺផ្តល់ជំនួយបឋម និងជំនួយរយៈពេលវែងជូនពួកគាត់ដើម្បីទទួលបានការគាំពារប្រកបដោយសុវត្ថិភាព។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាទៅលើប្រធានបទ "**ដំណើរការ និងការរៀបចំប្រព្រឹត្តទៅនាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**" រួចមកនាងខ្ញុំសូមធ្វើការបញ្ចេញមតិយោបល់ជាអនុសាសន៍ទៅលើបញ្ហាមួយចំនួនដូចតទៅៈ

**នាយកដ្ឋានសុខុមាលភាពសង្គមៈ**

- បន្តការអនុវត្តកម្មវិធី ក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលឱ្យបានខ្ជាប់ខ្ជួន
- គួរអនុវត្តនូវការអង្កេតពិនិត្យមើលជនដែលក្រីក្រ និងផ្តល់ជំនួយដល់ជនទាំងនោះ ដូចទៅនឹងជនអនាថាដែរជាពិសេសគ្រួសារក្រីក្រដែលមិនលទ្ធភាពឱ្យកុមារបានរៀនសូត្រ
- គួរមានយន្តការណាមួយដើម្បីផ្សព្វផ្សាយជាសាធារណៈអំពីជនរងគ្រោះអនាថា ព្រោះក្នុងករណីណាមួយជនរងគ្រោះអាចជួបនឹងគ្រួសារវិញ
- គួរបង្កើតយន្តការច្បាស់លាស់មួយក្នុងការត្រួតពិនិត្យជនអនាថាដែលត្រូវបានស្តារនីតិសម្បទាជូនគ្រួសារវិញ ជៀសវាងក្នុងករណីដែលមានអំពើហិង្សាកើតឡើង(ករណីជនអនាថាដែលជាជនវិបល្លាស្មារតី)
- បណ្តុះបណ្តាលមន្ត្រីឱ្យចំជំនាញ ដោយហេតុថាឈ្មោះជាអ្នកសង្គមកិច្ច គឺមានអត្ថន័យធំធេងណាស់ ព្រោះពួកគេត្រូវដាក់ទាំងកាយទាំងចិត្តក្នុងការធ្វើការជាមួយជនរងគ្រោះ
- គួរធ្វើការពិន័យទៅដល់ជនដែលបានបង្ខំកុមារ និងមនុស្សចាស់ឱ្យដើរសុំទាន ដើម្បីបានប្រាក់មកឱ្យខ្លួន។

**ប្រជាជន** បើទោះបីជាមាននាយកដ្ឋានក្នុងការអនុវត្តក៏ដោយ ក៏ត្រូវមានការចូលរួមពីសំណាក់ប្រជាជនៈ

- ផ្តល់ជាព័ត៌មាននានាអំពីជនរងគ្រោះទៅដល់មន្ត្រីជំនាញ ដើម្បីធ្វើការអនុវត្តផ្តល់ជាជំនួយដល់ជនរងគ្រោះ
- មិនគួរឱ្យប្រាក់ទៅជណសុំទាន ជាពិសេសគឺកុមារ ដោយហេតុថាកុមារភាគច្រើនបានជ្រើសរើសការដើរសុំទានជាជាងការទៅសិក្សា(ព្រោះបានលុយស្រួលជាង)។

ចំណុចដែលបានលើកឡើងនេះគ្រាន់តែជាការយល់ឃើញរបស់នាងខ្ញុំដែលជាអ្នកសិក្សាប៉ុណ្ណោះ ចំពោះការអនុវត្ត ការកែប្រែ នូវប្រការណាមួយជាសមត្ថកិច្ចរបស់ស្ថាប័នជំនាញ។

# ឯកសារយោង

# ឯកសារយោង


១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ចុះនៅខែកញ្ញាឆ្នាំ ២០១៨

២. សៀវភៅស្តីពីក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ អនុម័តនៅសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

៣. ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣, ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៨

៤. សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០១៩

៥. សៀវភៅកម្រងព័ត៌មានសេវាសារធារណៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

៦. សៀវភៅស្តីពីវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអង្កេតរហ័សនៃជនអនាថា ឆ្នាំ២០២០

៧. សៀវភៅស្តីពីគោលការណ៍ណែនាំសម្រាប់ជួយជនអនាថា, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។

# ឧបសម្ព័ន្ធ